# មតិយោបល់របស់អង្គការសង្គមស៊ីវិល
# លើសេចក្តីព្រាងទី១១ នៃ «ក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា»

ក្នុងនាមអង្គការសង្គមស៊ីវិល យើងខ្ញុំទាំងអស់គ្នា មានសេចក្តីរីករាយ និងសារទរជាខ្លាំង សម្រាប់វឌ្ឍនភាពនៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលប្រកបដោយភាពពេញលេញ និងការចូលរួមដ៏ធុលផុសពីសាធារណៈជន និងអ្នកពាក់ព័ន្ធ។ វឌ្ឍនភាពនៃសេចក្តីព្រាងចុងក្រោយ (ទី១១) នៃក្រមបរិស្ថាន និងធនធានធម្មជាតិ កាន់តែមានភាពល្អប្រសើរ ក៏ព្រោះតែភាពដឹកនាំនិងសុច្ឆ័ន្ទៈដ៏មុះមុតរបស់ថ្នាក់ដឹកនាំនៃក្រសួងបរិស្ថាន ជាពិសេសដោយការខិតខំប្រឹងប្រែងអស់ពីសមត្ថភាពនៃក្រុមមេធាវីវិស្ណុ។

យើងខ្ញុំទាំងអស់គ្នា ក៏បានចូលរួមយ៉ាងសកម្ម សំដៅជម្រុញឱ្យមានក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ឆ្លើយតបទៅនឹងស្ថានភាពសង្គម និងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជាយើង។ ដំណើរការពិនិត្យលើសេចក្តីព្រាងលើកទី១១នេះ យើងខ្ញុំបានធ្វើឡើងមាន ៣ដំណាក់កាលធំរួមមាន៖

១. ការពិនិត្យនិងផ្តល់យោបល់តាមវិស័យ/ផ្នែក ដោយអ្នកជំនាញការឯករាជ្យ លេខាធិការដ្ឋានវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងអង្គការសង្គមស៊ីវិលដែលជាសមាជិក និងដៃគូពាក់ព័ន្ធ។
២. ការពិគ្រោះយោបល់ជាមួយតំណាងសហគមន៍ បណ្តាញអង្គការសង្គមស៊ីវិល និងដៃគូពាក់ព័ន្ធ នៅថ្ងៃ១៧-១៨ ខែឧសភា ឆ្នាំ២០១៨។
៣. ការពិនិត្យផ្ទៀងផ្ទាត់ បូកសរុប និងសំយោគពីអ្នកជំនាញឯករាជ្យ និងការពិនិត្យដោយក្រុមតូចៗនៃបណ្តាញមុននឹងដាក់ជូនក្រសួងបរិស្ថាន។

ទោះបីមិនមានការពិគ្រោះយោបល់ជាសាធារណៈបន្តទៀតក៏ពិតមាន យើងខ្ញុំសូមគោរពផ្តល់ជាសំណូមពរចាំបាច់បន្ថែមទៀតលើសេចក្តីព្រាងទី១១ ដល់ក្រសួងបរិស្ថាន ដើម្បីធ្វើការពិចារណា និងដាក់បញ្ចូលនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ ក៏ដូចជាកិច្ចពិគ្រោះយោបល់អន្តរក្រសួង នាពេលខាងមុខនេះ ។

ទាំងនេះជាសេចក្តីសង្ខេបរួមនូវចំណុច ដែលគួរពិចារណា និងមតិយោបល់លម្អិតតាមមាត្រានីមួយៗ និងមានភ្ជាប់ជូនឯកសារតាមផ្នែក/វិស័យ។

មតិយោបល់ និងការកែសម្រួលសង្កត់ធ្ងន់លើ (១) គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) (២) ការចូលរួមជាសាធារណៈ (៣) ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (៤)ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ (៥) តំបន់ការពារធម្មជាតិ (៦) ការគ្រប់គ្រងរួមគ្នា និង (៧) មតិយោបល់ផ្សេងៗ។ ការវាយតម្លៃជារួមចំពោះ ការដាក់បញ្ចូលមតិយោបល់របស់អង្គការសង្គមស៊ីវិលក្នុងសេចក្តីព្រាងទី១១ គឺមានដូចខាងក្រោម៖

១. **គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC)**៖ គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិលប្រមាណ ៦០% បើប្រៀបធៀបនឹងសំណូមពររបស់អង្គការសង្គមស៊ីវិលលើសេចក្តីព្រាងទី១០។

- **ការរៀបចំពីសេចក្តីព្រាងហាក់ដូចជាមានការច្របូកច្របល់ធ្វើឱ្យមានការពិបាកក្នុងការពិនិត្យ ផ្ទៀងផ្ទាត់ខ្លឹមសារ។ ឧទាហរណ៍ដូចជា៖ មាត្រា១៨ នៃសេចក្តីព្រាងទី៩.១ បានប្តូរទៅមាត្រា១៧ នៃសេចក្តីព្រាងទី១០ ហើយមាត្រា១៧ នៃសេចក្តីព្រាងទី១០ បានប្តូរទៅមាត្រា១៨ នៃ សេចក្តីព្រាងទី១១ វិញ** (ជំពូក ២. គោលការណ៍ទូទៅៈ ក្នុងមាត្រា ១៨ ក្នុងសេចក្តីព្រាងទី ១១ ទំព័រ ៥)។
- **មាត្រា ១២៦ និង១២៧ ត្រូវបានលុបចោល ហើយមិនទាន់បង្ហាញពីហេតុផល និងពន្យល់ឱ្យបានច្បាស់លាស់នៅឡើយ** *(៤៨និង ៤៧ ការចូលរួមជាសាធារណៈ ទំព័រ ៥ជំពូក)*។

មតិយោបល់បន្ថែមគឺ សូមបញ្ចូល ទាំងជនជាតិដើមភាគតិច និងជនជាតិខ្មែរ ដែលរងផលប៉ះពាល់ផ្ទាល់និងប្រយោល ដើម្បីទទួលបានព័ត៌មានពីគម្រោងអភិវឌ្ឍន៍។ ស្នើឱ្យផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់សហគមន៍ធ្វើការសម្រេចចិត្ត ព្រមទាំងបន្ថែមពាក់ព័ន្ធនឹងសិទ្ធិ<u>សង្គម វប្បធម៌ និងសេដ្ឋកិច្ច</u> ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវការគំរាមកំហែង ការបោកបញ្ឆោត ឬការបង្ខិតបង្ខំពីការផ្លាស់ប្តូរទីលំនៅថ្មី ករណីដែលតម្រូវឱ្យមានការផ្លាស់ប្តូរទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ការលេចធ្លាយឧស្ម័នពុល តំបន់អសន្តិសុខ តំបន់មានគ្រោះមហន្តរាយធ្ងន់ធ្ងរ ជាដើម។

២. **ការចូលរួមជាសាធារណៈ**៖ មានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិល ប្រមាណ ១៨% បើប្រៀបធៀបនឹងសំណូមពររបស់អង្គការសង្គមស៊ីវិលលើសេចក្តីព្រាងទី១០។

មតិយោបល់បន្ថែមសំខាន់នោះគឺ ចំពោះការចូលរួមក្នុងកិច្ចដំណើរការរបស់គម្រោងអភិវឌ្ឍន៍នីមួយៗ គឺតម្រូវឱ្យធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរផ្ញើរទៅជូនអាជ្ញាធរមូលដ្ឋានដើម្បីធានាពីការចូលរួមដឹងឮពីផលប៉ះពាល់ ក៏ដូចជាផលចំណេញដែលបានពីគម្រោង ជាពិសេស គឺត្រូវធានាថាមានព័ត៌មានគ្រប់ជ្រុងជ្រោយ និងមានការផ្តល់ឱកាសឱ្យសមាជិកសហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីបានចូលរួមពេញលេញក្នុងការសម្តែងមតិ និងផ្តល់មតិយោបល់ប្រកបដោយតម្លាភាពនិងគណនេយ្យភាព។ ស្នើឱ្យបញ្ចូលចំណុចមួយទៀត គឺ <u>រាល់គម្រោងអភិវឌ្ឍន៍ និងផែនការវិនិយោគបាននិងកំពុងអនុវត្ត ដោយពុំមានការចូលរួមជាសាធារណៈ ឬមិនបានពេញលេញត្រូវផ្អាកជាបណ្តោះអាសន្ន និងត្រូវរៀបចំផែនការនិងអនុវត្តន៍ ការចូលរួមជាសាធារណៈឱ្យបានពេញលេញក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីក្រមនេះចូលជាធរមាន។</u>

៣. **ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ** ៖ គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់អង្គការសង្គមស៊ីវិល ប្រមាណ ៣៣% ដូចជាក្នុងមាត្រា៧៥ និងមាត្រា៧៦ នៃសេចក្តីព្រាងច្បាប់ទី១១ បើប្រៀបធៀបនឹងសំណូមពររបស់អង្គការសង្គមស៊ីវិលលើសេចក្តីព្រាងទី១០។ មតិយោបល់សំខាន់ដែលត្រូវពិចារណា គឺត្រូវធានាថាមានការចូលរួមពីសាធារណជន និងក្រុមប្រឹក្សាឯករាជ្យ និងគ្រប់ភាគីពាក់ព័ន្ធក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ហើយការប្រែប្រួលអាកាសធាតុ

ការគិតគូរពី យេនឌ័រ ស្ត្រី កុមារ ជនពិការ ចាស់ជរា គួរតែបានដាក់បញ្ចូលធ្វើការវិភាគក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។

- លំហូរ (លំដាប់លំដោយ) នៃមាត្រាមិនទាន់ត្រឹមត្រូវ ឧ. មាត្រា៧៣ គួរដាក់មុនមាត្រា៧២។
- ស្នើឱ្យបន្ថែមមាត្រាចែងពីគោលបំណងនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ
- តើថវិកានៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រដោយក្រសួងទទួលបន្ទុកអាទិភាពបានមកពីប្រភពណា?

៤. **ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ** ៖ គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិលប្រមាណ ៥៥%។ ទាក់ទងនឹង **ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ** ច្បាប់គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ គោលការណ៍សេនដាយ (Sendai Framework) គួរដាក់បញ្ចូលបន្ថែមក្នុងសេចក្តីព្រាងក្រម ជាពិសេសគឺ ការធានាថាមានកញ្ចប់ថវិកា សម្រាប់ការអនុវត្ត CCA & DRR ដែលជាការវិភាជន៍ថវិកាជាតិដាច់ដោយឡែក ដើម្បីប្រើប្រាស់លើការងារគ្រប់គ្រង និងការឆ្លើយតបហានិភ័យគ្រោះមហន្តរាយ ដោយមិនចាំបាច់ត្រូវរង់ចាំជំនួយពីខាងក្រៅដើម្បីរួមបញ្ចូលជាមួយថវិកាអភិវឌ្ឍន៍ឃុំ/សង្កាត់។

៥. **តំបន់ការពារធម្មជាតិ** ៖ គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិលជាង៥០%។ ទោះយ៉ាងណាក៏ដោយ ក្រុមពិភាក្សាបានពិនិត្យឃើញមានការកែលម្អចំពោះមាត្រាមួយចំនួនដូចជា៖

- **មាត្រា ៣១១** ការកំណត់តំបន់គ្រប់គ្រង ចំណុចទី៤ តំបន់សហគមន៍ (Community Zone) ក្នុងចំណុចទី៤ តំបន់សហគមន៍ ស្នើសុំដាក់បញ្ចូលដីលំនៅដ្ឋាន វាលស្រែ វាលចម្ការ ឬចម្ការវិលជុំ ដីអារក្ស ដីកប់សព និងដីបម្រុងទុក មិនត្រូវចាត់ចូលជាតំបន់សហគមន៍ឡើយ អនុលោមតាម ច្បាប់តំបន់ការពារធម្មជាតិ ឆ្នាំ២០០៨។
- **មាត្រា៣៨១ និង មាត្រា៣៨២** គួរពិគ្រោះយោបល់ ជាសាធារណៈមិនគួរពិគ្រោះយោបល់ ជាមួយតែភាគីពាក់ព័ន្ធទេ ព្រោះមិនគ្រប់គ្រាន់។
- **មាត្រា៣៨៩** សូមចែងមាត្រាបែងចែកឱ្យច្បាស់លាស់ ដោយកំណត់៥០% នៃតម្លៃសរុបសម្រាប់សហគមន៍។
- **មាត្រា៤១១ ដល់ មាត្រា៤១៣** យោបល់សូមពិចារណា ពីការទាញយកអនុផលព្រៃឈើ មកបម្រើកម្រិតជីវភាពប្រចាំថ្ងៃ ការហាមដាច់ខាតការធ្វើឱ្យប៉ះពាល់ដល់កសិករតូចតាច (ឧ.ដើមអង្កាសីល ដើមអរគីដេ ដើមប្រង់…) គួរកំណត់ទំហំ និងបរិមាណជាក់លាក់ ក្នុងការហាមឃាត់។

៦. **ការគ្រប់គ្រងរួមគ្នា** ៖ គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់អង្គការសង្គមស៊ីវិល ប្រមាណ ៨០% ដោយសង្កេតឃើញថា រវាងសេចក្តីព្រាងទី១០ និង ទី១១ គឺមានភាពខុសគ្នាច្រើន។

**សំណូមពរបន្ថែម៖**

- មាត្រា៣៤០ ក្នុងកំណែទី១១ បន្ថែមខ្លឹមសារលម្អិតជាងមុន។
- សូមឱ្យដកឃ្លា "ដីបម្រុងទុករបស់ជនជាតិដើមភាគតិច ឬដីជាលក្ខណៈប្រពៃណីដទៃទៀត" ព្រោះដីនេះ គឺជាដីឯកជនរបស់សហគមន៍ជនជាតិដើមភាគតិច។
- គប្បីធ្វើការកែលំអបន្ថែមទៀត ចំពោះស្ថាប័នមានសមត្ថកិច្ចរួមបញ្ចូល សហគមន៍ និងអង្គការសង្គមស៊ីវិល ដែលបានចូលរួមគ្រប់គ្រងធនធានធម្មជាតិ។

**៧. មតិយោបល់ផ្សេងៗ៖**

- ជាទូទៅនៅតែមានកំហុសអក្ខរាវិរុទ្ធ ឃ្លាឃ្លោង ជាពិសេសសូមពិនិត្យកែសម្រួលឃ្លា ល្បះឱ្យមានលក្ខណៈនិងបែបបទជាភាសាខ្មែរផ្លូវការ (វិធានច្បាប់) ជាជាងប្រើប្រាស់ទម្រង់អង់គ្លេសបែបអសកម្មលើប្រធានបទ។
- ចំពោះការចូលរួមជាសាធារណៈ គឺតម្រូវឱ្យមានការចូលរួមទាំងសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍រងផលប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោល ហើយមានការចូលរួមគ្រប់ដំណាក់កាលនៃការអនុវត្តគម្រោងរួមមាន (១) ដំណាក់កាលសិក្សាស្រាវជ្រាវបឋម (២) ដំណាក់កាលរៀបចំគម្រោង (៣) ដំណាក់កាលអនុវត្តន៍ និង (៤) ដំណាក់កាលបញ្ចប់គម្រោង។
- ចំពោះការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ គឺត្រូវធ្វើការកែលម្អទាក់ទងនឹងការកំណត់វិសាលភាព និងដែនសមត្ថកិច្ចនៃស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការធ្វើការរួមគ្នា ដើម្បីជៀសវាងការជាន់តួនាទីរវាងស្ថាប័នមួយទៅស្ថាប័នមួយទៀត។ ជាងនេះទៅទៀត ត្រូវផ្តល់សិទ្ធិឱ្យសហគមន៍ចូលរួមជាមួយអង្គការសង្គមស៊ីវិល និងស្ថាប័នរាជរដ្ឋាភិបាលដើម្បីធ្វើការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។
- ស្នើសុំឱ្យមានការពិចារណាបន្ថែម ក្នុងសេចក្តីព្រាងបន្ទាប់ទាក់ទងនឹងការចាត់វិធានការ និងយន្តការនានា ក្នុងការគ្រប់គ្រង និងការអនុវត្តការប្រើប្រាស់សារធាតុគីមីកសិកម្ម ដែលបំពុលដល់ដី និង ទឹក។

- ស្នើសុំឱ្យមានការបញ្ចូលធនធានជលផល និងការគ្រប់គ្រងធនធានជលផលទៅក្នុងសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិដើម្បីជាផលប្រយោជន៍រួម ក្នុងការធានាដល់ភាពកាន់តែប្រសើរឡើងនូវការគ្រប់គ្រងបរិស្ថាន ទឹក និងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងពេលបច្ចុប្បន្ន និងពេលអនាគត។

(ចំពោះមតិយោបល់លំអិត សូមពិនិត្យក្នុងតារាងមតិយោបល់របស់អង្គការសង្គមស៊ីវិល ដែលមានភ្ជាប់ជូនជាមួយ)

# <u>មតិយោបល់របស់អង្គការសង្គមស៊ីវិល</u>

## <u>លើសេចក្តីព្រាងទី១១ នៃក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា</u>

## ប្រធានបទ៖ ការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

| លរ NO | សំណូមពរ/កំណែប្រែថ្មី លើពង្រាងទី ១០ (CSO Suggestions ) | គន្លី/មាតិកា/ជំពូក Book/Title | មតិយោបល់/សំណូមពរ/កំណែប្រែថ្មី លើសេចក្តីព្រាងទី១១ ( Reviewer Suggestions ) |
|---|---|---|---|
| | មាត្រាទី១៥៣............ស្នើសុំ បញ្ចូលពាក្យ នៅត្រង់ឃ្លាដែល បញ្ជាក់ពីដៃគូរពាក់ព័ន្ធ ទាំងអស់ រួម <u>ទាំងវិស័យឯកជន</u> ដោយសារពួក គាត់គឺជាកំលាំងចលករ និងអង្គការ ពាក់ព័ន្ធមួយយ៉ាងសំខាន់។ ទាំងនៅ ក្នុងការរៀបចំផែនការ និង អនុវត្ត ដោយមានការមួយចំនួនធំដើម្បីអោ យមាននិរន្តរភាព ចំបាច់ត្រូវផ្សារ ភ្ជាប់វិស័យឯកជន ទាំងនៅថ្នាក់ជាតិ និងជាពិសេសនៅថ្នាក់ក្រោមជាតិ។ | មាត្រាទី១៥៩. _ ការឆ្លើយតប ការប្រែប្រួលអាកាសធាតុ ............ដើម្បីដោះស្រាយអំពី មាត្រាទី១៨៨. _ការលើកកម្ពស់ ......ក្រុមប្រឹក្សាជាតិ.......ចំពោះ ការប្រែប្រួលអាការធាតុ | អាចទទួលយកបាន (ប្តូរទៅមាត្រា១៥៩ និង ១៨៨) |

| | | | |
|---|---|---|---|
| | មាត្រាទី១៥៩ និង មាត្រាទី១៨១ ស្នើសុំបន្ថែម-............................ ចំពោះការប្រែប្រួលអាកាសធាតុ រវាងក្រសួងស្ថាប័នមាន សមត្ថកិច្ច និងអ្នកពាក់ព័ន្ធសាធារណៈ។ | មាត្រា១៦៤._កិច្ចសហការ...... ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | អាចទទួលយកបាន បានដាក់បញ្ចូលហើយ (ប្តូរទៅមាត្រា១៦៤) |
| | **មាត្រា១៦០** ._ ការប្រែប្រួលអាកាសធាតុក្នុងសកម្មភាពអនុវត្ត ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរួមបញ្ចូលនូវការពិចារណាអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការកំណត់នូវរាល់សកម្មភាពអនុវត្តទាំងអស់ និងពិចារណាទៅលើផលប៉ះពាល់នៃសកម្មភាពនោះ ដែលនាំទៅរក ការប្រឈមទៅនឹងហានិភ័យអាកាសធាតុ ជាពិសេសសមត្ថភាពបន្សាំ ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវផ្តល់ដំបូន្មានផ្នែកបច្ចេកទេសទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធទៅលើការកំណត់នូវសកម្មភាពអនុវត្តន៍ រួមមានវិធាន | មាត្រា១៦៣. _ការអនុវត្ត......... ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព.......ចំពោះការប្រែប្រួលអាកាសធាតុ<br><br>មាត្រា១៦៥._ការធ្វើសេចក្តីសម្រេច......ក្រសួង ស្ថាប័នមានសមត្ថកិច្ច | អាចទទួលយកបាន មានការបញ្ជាក់ក្នុងមាត្រា១៦៣ និង មាត្រា១៦៥ |

| | | | |
|---|---|---|---|
| | ការណ៍ បច្ចេកទេស និង ដំណើរការឆ្លើយតបទៅ តាមផ្នែកជាក់លាក់មួយៗជាអាទ៍ ។<br> (សូមពិនិត្យមតិយោបល់របស់សង្គមស៊ីវិលលើសេចក្តីព្រាងទី ៩.១) | | |
| | មាត្រា១៦៦<br><br>ស្នើបន្ថែមៈ ក្នុងសកម្មភាពតាមដាននិងវាយតម្លៃ គួរតែមានការចូលរួមពីសង្គមស៊ីវិល និង វិស័យឯកជន។ | មាត្រា១៦៨. _សកម្មភាពអង្កេត......ក្រុមប្រឹក្សាជាតិ...និងវាយតម្លៃការប្រែប្រួលអាកាសធាតុ តាមវិស័យនីមួយៗ<br><br>មានត្រា១៨៨._ការលើកកម្ពស់......ក្រុមប្រឹក្សាជាតិ.......ចំពោះការប្រែប្រួលអាការធាតុ | មាត្រា១៦៨<br>ស្នើបន្ថែមៈ ក្នុងសកម្មភាពតាមដាននិងវាយតម្លៃ គួរមានការចូលរួមពីសង្គមស៊ីវិល និង វិស័យឯកជន។ |
| | **មាត្រា១៦៧** ._ ការរៀបចំរបាយការណ៍ស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ<br>រាល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវវាយការណ៍ឲ្យទាន់ពេលវេលាទៅកាន់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរ | មាត្រា១៦៩._ ការរៀបចំរបាយការណ៍......និងវាយតម្លៃ......ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ចីរភាព | មានការបែកចែកកថាខណ្ឌច្បាស់លាស់<br>មាត្រា១៦៩<br><br>ស្នើរសុំបន្ថែមចំនុចទី៤ៈ បញ្ជាក់ពីកាលបរិច្ឆេទ និងយន្តការអោយបានច្បាស់លាស់ (១ឆ្នាំ/ម្តង) |

| | | | |
|---|---|---|---|
| | ភាពស្តីពីបច្ចុប្បន្នភាពដែលសម ស្របទៅនឹងសូចនករពាក់ពន្ធ័នៃ ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិ លិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធ នឹងការប្រែប្រួលអាកាសធាតុដទៃទៀត និងស្តីពីក្របខ័ណ្ឌស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ តាមវិស័យ ស្របជាមួយនឹងលិខិតបទដ្ឋានគតិយុត្ត។ របាយការណ៍នេះ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ដែលមានចែងក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។<br><br>មាត្រា ១៨៧ ក្នុងពង្រាងទី១០ មិនទាន់ទទួលយកមតិយោបល់ | | |

| | | | |
|---|---|---|---|
| | មាត្រា ១៨៨ ក្នុងសេចក្តីព្រាង១០ មិនទាន់ទទួលយកមតិយោបល់ | មាត្រា១៧០._ កាតព្វកិច្ចរៀបចំរបាយការណ៍ជាអន្តរជាតិ........ កិច្ចព្រមព្រៀង......ពីការប្រែប្រួលអាកាសធាតុ | អាចទទួលយកបាន បានប្តូរមកមាត្រា ១៧០ |
| | ពត៌មានស្តីពីការប្រែប្រួលអាកាសធាតុ<br>មាត្រាទី ១៩១ ក្នុងពង្រាងទី១០<br><br>ស្នើឱ្យពិនិត្យមតិយោបល់របស់សង្គមស៊ីវិលបន្ថែម លើសេចក្តីព្រាងទី ៩.១ | ជំពូកទី៥<br>មាត្រា ១២១._ ការវាយតម្លៃ......គម្រោង...<br>មាត្រា១៧៣_ សកម្មភាព...ក្រុមប្រឹក្សាដោយចីរភាព............ | ប្តូរមកមាត្រា១២១ និង ១៧៣<br><br>→ស្នើឱ្យពិនិត្យមតិយោបល់របស់សង្គមស៊ីវិលបន្ថែម លើសេចក្តីព្រាងទី ៩.១<br><br>សំណូមពរៈ ការប្រមូលពត៌មានអាកាសធាតុ គឺធ្វើឡើយដោយមានលក្ខណៈវិទ្យាសាស្ត្រ និងទុកចិត្តបានដូចជា (ការវាយតំលៃកាត់បន្ថយភាពងាយរងគ្រោះ VRA) ដែលមានចូលរួម និង ការរៀបចំផែនការបន្សាំ និងការកាត់បន្ថយហេតុ ពីមូលដ្ឋាន<br><br>ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ មានជាអាទ៍ៈ<br>ក-ពត៌មានគ្រោះហានិភ័យពាក់ព័ន្ធទៅនឹងអាកាសធាតុ សេណារីយ៉ូនៃ ការប្រែប្រួលអាកាសធាតុ និងការវាយតម្លៃភាពងាយរងគ្រោះ<br>ខ-ជម្រើស លទ្ធភាព និងសមត្ថភាព ក្នុងការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ |

| | | | |
|---|---|---|---|
| | | | គ-កម្រិត ប្រភព និងកត្តានានា អំពីការបំភាយឧស្ម័នផ្ទះកញ្ចក់ តាមវិស័យ ជាពិសេស វិស័យថាមពល ព្រៃឈើ និងកសិកម្ម ។<br>ង-ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដែលមានចែងនៅក្នុង យន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល ។<br>ច- គម្រោង និងអន្តរគមន៍នានាដែលពាក់ព័ន្ធទៅនឹងការ កាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលមានប្រតិបត្តិការនៅក្នុង ព្រះរាជាណាចក្រកម្ពុជា រួមទាំង ការពិនិត្យតាមដានហិរញ្ញប្បទាននានាដែលទទួលបានផងដែរ។<br>ឆ-ការអនុវត្តល្អក្នុងការកាត់បន្ថយ និងការបន្សាំដែលស្របតាមបរិបទនៃព្រះរាជាណាចក្រកម្ពុជា មានជាអាទិ៍ ប្រសិទ្ធភាព ប្រសិទ្ធផល និងភាពសន្សំសំចៃនៃការធ្វើអន្តរាគមន៍ និងមេរៀនដែលបានយល់ដឹងពីគម្រោងនិងអន្តរាគមន៍ដែលបានអនុវត្តន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមាន ការសាកល្បង ឬការដកពិសោធន៍បច្ចេកវិទ្យានានាក្នុងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំថ្មីៗ ជាអាទិ៍។ |

| | | | |
|---|---|---|---|
| | មាត្រា ១៩៦ ប្រព័ន្ធព័ត៌មានដែល សាធារណៈជនអាចស្វែងរកបាន<br><br>ស្នើឱ្យពិនិត្យមតិយោបល់របស់សង្គមស៊ីវិលបន្ថែម លើសេចក្តីព្រាងទី ៩.១ | មាត្រា១៧៧._ប្រព័ន្ធ ព័ត៌មាន…….. ក្រុមប្រឹក្សាជាតិ…….ដើម្បីប្រមូលផ្តុំ…. | មាត្រា១៧៧ ប្រព័ន្ធព័ត៌មានដែលសាធារណៈអាចស្វែងរកបាន<br><br>ស្នើឱ្យពិនិត្យមតិយោបល់របស់សង្គមស៊ីវិលបន្ថែមលើ សេចក្តីព្រាងទី ៩.១<br>- ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឲ្យសាធារណជន អាចប្រើប្រាស់បាននូវព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទាំងឡាយទៅតាមវិស័យរបស់ខ្លួន ព្រមទាំងព័ត៌មានអំពីការអនុវត្តការធ្វើអន្តរាគមន៍ទៅលើការប្រែប្រួលអាកាសធាតុ រួមមានលទ្ធផលទាំងឡាយដោយផ្អែកលើសូចនករអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធ និងមេរៀនដែលបានយល់ដឹងពីការអនុវត្តសកម្មភាព នានា ជាអាទិ៍ ។<br>- ព័ត៌មាននេះត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន/ដឹង/លឺ ស្របតាមបទបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន |
| | មាត្រា១៨៥៖ ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គល<br><br>សូមពិនិត្យមតិយោបល់លើពង្រាងទី៩.១ | | មាត្រា ២១២. _ គោលបំនងការវាយតម្លៃហានិភ័យ ត្រូវអនុវត្តដើម្បី |

| | | | |
|---|---|---|---|
| | យន្តការកសាងចំណេះដឹង និងការលើកម្ពស់ការស្រាវជ្រាវ | | សូមពិនិត្យមតិយោបល់លើពង្រាងទី៩.១ |
| | ការបែងចែកថវិការជាតិសម្រាប់ការឆ្លើយតបការប្រែប្រួលអាកាសធាតុ<br><br>ប៉ុន្តែស្នើសុំអោយមានកញ្ចប់ថវិការដាច់ដោយឡែកដែលវិភាគធន៍ពីថវិការជាតិ សំរាប់សកម្មភាព DRR/CCA **នៅតាមមូល**ដ្ឋានសហគមន៍ | ១៨៤ ដល់ ១៨៧. _ ការរៀបចំក្របខ័ណ្ឌ…..សេដ្ឋកិច្ច… ការលើកកម្ពស់ | ស្នើរសុំអោយមានកញ្ចប់ថវិការ ដាច់ដោយឡែកដែលវិភាធន៍ពីថវិការជាតិ សំរាប់សកម្មភាព DRR/CCA **នៅតាមមូល**ដ្ឋានសហគមន៍<br><br>គួរតែបន្ថែមការស្នើសុំថវិការទៅលើការអនុវត្តការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ |
| | ការលើកកំពស់ការវិនិយោគលើការអាកាសធាតុដែលឆ្លាតវៃ<br><br>ក្រុមស្នើសុំអោយមានមាត្រាច្រើនជាងនេះស្តីពីការលើកទឹកចិត្តដល់វិស័យឯជនដែលវិនិយោគលើអាកាសធាតុដែលមានលក្ខណវ៍យឆ្លាត ដូចជា បង្កើតបរិយាកាសអំណោយផល លើកទឹកចិត្ត គាំទ្រ | មាត្រា១៨៨._ ការផ្លាស់ប្តូរចំណាត់ថ្នាក់………ស្ថាប័នទទួលបន្ទុកបរិស្ថាន…….ស្តីពីការបាត់បង់….. | បានដាក់បញ្ចូលនៅផ្នែកទី២ មាត្រា១៨៨ |

| | | | |
|---|---|---|---|
| | និងអនុគ្រោះដល់វិស័យឯកជន សង្គមស៊ីវិល ឬសហគមន៍ ដែលវិនិយោគអាកាសធាតុ ដែលមានលក្ខណ:វៃឆ្លាត | | |
| | ការអង្កេតតាមដានហិរញ្ញវត្ថុ ប្រែប្រួលអាកាសធាតុបរទេស<br><br>ហិរញ្ញវត្ថុ ឬហិរញ្ញប្បទាន???<br>ការកៀងគរថវិការ គួរតែបញ្ជាក់អោយបានច្បាស់ | មាត្រា១៨៩ និង ១៩០៖_ ការលើកកម្ពស់ការវិនិយោគ…….<br>ក្រុមប្រឹក្សាជាតិ……….<br>_ ការសម្របសម្រួលអំពីហិរញ្ញប្បទាន….. ការប្រែប្រួលអាកាសធាតុ…..សហការក្រសួង<br>ស្ថាប័ន…… | អាចទទួលយកបាន |
| | អាជ្ញាធរជាតិដែលត្រូវបានចាត់តាំង<br><br>សូមពិនិត្យមតិយោបល់លើពង្រាងទី ៩.១ | មាត្រា១៩១._ យន្តការដែលចូលរួមវិភាគទាន…............និងការគាំទ្រការអភិវឌ្ឍន៍ដោយចីរភាព | យើងគាំទ្រការចែងក្នុងមាត្រា១៩១ និង១៩២នេះ តែ សូមបន្ថែម៖ អនុលោមតាមផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្រ្តជាតិស្ដីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនានា |
| | ការលើកកម្ពស់ការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុដែលផ្អែកលើលទ្ធផល<br><br>សូមពិនិត្យមតិយោបល់លើពង្រាងទី | មាត្រា១៩២._ ការលើកកម្ពស់ការចូលរួម…..កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់…… | យើងគាំទ្រការចែងក្នុងមាត្រា១៩២នេះ តែ សូមបន្ថែមនៅចំនុចទី៣៖ .........ដែលបានកៀងគរតាមរយ:ការចូលរួមរបស់អង្គភាពរដ្ឋ អង្គភាពឯកជន និងដៃគូអភិវឌ្ឍន៍នានា នៅក្នុងយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល និងលទ្ធផលផ្សេងៗដែលសម្រេច |

| | | | |
|---|---|---|---|
| | ៩.១ | | បានជាអាទិ៍ ។ |

| | |
|---|---|
| | **មតិយោបល់ថ្មី ក្នុងសេចក្ដីព្រាងទី១១**<br>**មាតិកាទី២ ការប្រែប្រួលអាកាសធាតុ នៃសេចក្ដីព្រាងទី១១**<br>**ជំពូក២** គួរបន្ថែម មាត្រា ១៦២ …..ប្តូរពី**ការយកចិត្តទុកដាក់មក** ដោយ **ផ្អែកលើរបាយការណ៍អំពីផលប៉ះពាល់ និង ដំណោះស្រាយពីគ្រប់ប្រភព**<br><br>**ជំពូក៣**<br>**មាត្រា ១៦៣**<br>សូមបន្ថែមៈ<br>- ទប់ស្កាត់បទល្មើសព្រៃឈើនៅសហគមន៍អោយមានប្រសិទ្ធភាពបំផុត<br>- បន្ថែម**សង្គមស៊ីវិល និង សហគមន៍មូលដ្ឋាន**<br><br>**មាត្រា ១៨៣**<br>សូមរក្សាយន្តការធានាការទូទាត់ថ្លៃលក់កាបូន ដោយសមធម៌ និងសមរម្យបំផុត ព្រមទាំងបញ្ជាក់ពីចំនួនភាគរយនៃការបែងចែកផលប្រយោជន៍នៃការលក់កាបូនសំរាប់សហគមន៍មូលដ្ឋាន ទៅលើយន្តការកាត់បន្ថយការបញ្ចេញឧស្មន័ផ្ទះកញ្ចក់<br><br>**ជំពូក៦**<br>- ផ្នែកទី២ មាត្រា ១៨៨ គួរបញ្ចូល**អង្គការសង្គមស៊ីវិល និង សហគមន៍មូលដ្ឋាន**<br>- ផ្នែកទី៣ មាត្រា ១៩០ គួរមាន**ការធ្វើសវនកម្ម**លើហិរញ្ញប្បទានទាក់ទងនឹង ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ (**គួរមានក្រុមសវនកម្ម** |

| | |
|---|---|
| | **ឯករាជ្យ អាចក្នុងស្រុក និង ក្រៅស្រុក**)<br>- ផ្នែកទី៩ មាត្រា ១៩១ និង ១៩២ សូមរក្សា **យន្តការទូទាត់លក់កាបូន**ក្នុងការសម្រេចចិត្តពីសហគមន៍ |
| | **មតិយោបល់ថ្មីក្នុងគន្លឹទី៣ មាតិកាទី១**<br><br>**មាត្រា១៤៨ ._ វិសាលភាព**<br>**សូមបន្ថែម៖**<br>មាតិកានេះមានវិសាលភាពអនុវត្តចំពោះសកម្មភាព ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។<br>.....យន្តការនៃការដឹកនាំការគ្រប់គ្រង .......<br><br>**មាត្រាទី១៤៩**<br>ស្នើសុំកែប្រែពាក្យពី (គ្រប់គ្រងគ្រោះមហន្តរាយ)ទៅជា គ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ (from “disaster management” to “disaster risk management” ) ដោយនៅក្នុងពាក្យនេះ មានរួមបញ្ចូលនៅការត្រៀមបង្ការ ដើម្បីកាត់បន្ថយគ្រោះភ័យ និង គ្រោះមហន្តរាយ។<br>សូមបញ្ចូលការបញ្ជ្រាប ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ជាមួយនិង ការប្រែប្រួលអាកាសធាតុ ទៅក្នុងការរៀបចំផែនការរយៈពេលវែង<br>**ស្នើសុំបញ្ចូល៖** អង្គការសង្គមស៊ីវិល ក្នុងការរៀបចំផែនការ និង ពិគ្រោះយោបល់ (បើអត់មានបញ្ជាក់អំពីការចូលរួមរបស់សង្គមស៊ីវិលដូចជាមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយពីដៃគូរពាក់ព័ន្ធ)។<br>សូមបន្ថែម សហគមន៍មូលដ្ឋានផងដែរ ....... ពីព្រោះពួគគេជាអ្នករងគ្រោះ និង មានបទពិសោធន៍ក្នុងគ្រោះមហន្តរាយ។<br><br>**មាត្រាទី១៥០ ៖** ការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលប៉ះពាល់ដល់បរិស្ថាន |

ត្រូវ ផ្អែកតាមរយៈច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (អនុម័តិ ខែ កក្កដា ឆ្នាំ ២០១៥) ត្រូវលើកយកបញ្ចូក់ ដើម្បីអនុវត្ត ពង្រឹងការចូលរួមទទួលខុសត្រូវ នៅតាមសាមីក្រសួងក្នុងការរៀបចំ ចាត់តាំងអោយមានលេខាធិការដ្ឋានទទួលខុសត្រូវលើការងារ គ្រប់គ្រងគ្រោះមហន្តរាយ អោយមានប្រសិទ្ធភាពខ្ពស់ ផ្សារភ្ជាប់ជាមួយនៅថវិកាសម្រាប់អនុវត្ត៕

សូមបន្ថែម

ការវាយតម្លៃ គួរតែមានគណៈកម្មការវាយតម្លៃដោយឯករាជ្យ ជាក្រុមការងារចម្រុះ( ស្ថាប័នជាតិ ថ្នាក់ជាតិ និងក្រោមជាតិ វិស័យឯកជន អង្គការសង្គមស៊ីវិល និង សហគមន៍មូលដ្ឋាន

**មាត្រា ១៥២៖** ការពិគ្រោះយោបល់ស្តីពីការគ្រប់គ្រង និងកាត់បន្ថយហានិភ័យ

**គួរបន្ថែម** កិច្ចសហការថ្នាក់តំបន់ និង អន្តរជាតិ ជាពិសេសគឺ ការឆ្លើយតបបន្ទាន់ ឬ ការព្យាករណ៍ជាមុនពីហានិភ័យគ្រោះមហន្តរាយ

**គួរបន្ថែម** ការរៀបចំកញ្ចប់ថវិកាសម្រាប់ការសង្គ្រោះបន្ទាន់ ឬ ការឆ្លើយតបនឹងផ្ទែកមនុស្សធម៌ ជាជាងការរំពឹងតែពីជំនួយរបស់កាកបាទក្រហម និង ជំនួយខាងក្រៅផ្សេងៗទៀត ដែលអាចធ្វើឱ្យសកម្មភាពឆ្លើយតបមានការយឺតយ៉ាវ។

**មាត្រាទី១៤៩ និង១៥២**

**ស្នើសុំបញ្ចូល** អង្គការសង្គមសីវិល ក្នុងការរៀបចំផែនការ និង ពិគ្រោះយោបល់ (បើអត់មានបញ្ជាក់អំពីការចូលរួមរបស់សង្គមសីវិលដូចជាមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយពីដៃគូរពាក់ព័ន្ធ)។ បន្ថែម សហគមន៍មូលដ្ឋានផងដែរ ……. ពីព្រោះពួគគេជាអ្នករងគ្រោះ និង មានបទពិសោធន៍ក្នុងគ្រោះមហន្តរាយ

គួរបន្ថែម កិច្ចសហការថ្នាក់តំបន់ និង អន្តរជាតិ ជាពិសេសគឺ ការឆ្លើយតបបន្ទាន់ ឬ ការព្យាករណ៍ជាមុនពីហានិភ័យគ្រោះមហន្តរាយ

គួរបន្ថែម ការរៀបចំកញ្ចប់ថវិកាសម្រាប់ការសង្គ្រោះបន្ទាន់ ឬ ការឆ្លើយតបនឹងផ្ទែកមនុស្សធម៌ ជាជាងការរំពឹងតែពីជំនួយរបស់កាកបាទក្រហម និង ជំនួយខាងក្រៅផ្សេងៗទៀត ដែលអាចធ្វើឱ្យសកម្មភាពឆ្លើយតបមានការយឺតយ៉ាវ។

| | |
|---|---|
| | **មាត្រា១៩៣** .ការប្រើប្រាស់ដោយចីរភាព<br>សូមណូមពរ សុំរក្សាមាត្រា២១៥ចាស់ ទំព័រ ៧៣ ជំពូក២<br>បន្ថែម<br>ចំនុចទី៦ ឧស្ម័នបំពុល/ ផ្ទះកញ្ចក់<br>ចំនុចទី៧ សារធាតុគីមីកសិកម្ម លើដី និងក្នុងទឹក<br>ពន្យល់បន្ថែម<br>មាត្រា២១៣ ទំព័រ៨០ ពន្យល់ពាក្យ "**កូតាសម្រាប់ការយកផលិតផលត្រឡប់មកវិញ**" ។<br>សូមពន្យល់អត្ថន័យ **អ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល** នៅក្នុងសទានុក្រម |

# <u>មតិយោបល់របស់អង្គការសង្គមស៊ីវិល</u>

## <u>លើសេចក្តីព្រាងទី១១ នៃក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា</u>

## ប្រធានបទ ៖ ការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ

| លរ | មតិយោបល់/សំណូមពររបស់សង្គមស៊ីវិលលើសេចក្តីព្រាងទី១០ | គន្លី/មាតិកា/ជំពូកនៃសេចក្តីព្រាងទី១១ | មតិយោបល់/សំណូមពរ/កំណែប្រែថ្មីលើសេចក្តីព្រាងទី១១ |
|---|---|---|---|
| | មាតិកាទី២៖<br>ការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ<br>**ជំពូកទី១៖ ការរៀបចំយន្តការ គ្រប់គ្រងរួមគ្នា** | មាតិកាទី៣៖ ការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ<br>**ជំពូកទី១៖ ការបង្កើតក្របខ័ណ្ឌគ្រប់គ្រងរួមគ្នា** | ក្នុងកំណែ១០ មាន៥ជំពូក មាន២២មាត្រា<br>ក្នុងកំណែ១១ មាន៣ជំពូក មាន២៥មាត្រា |
| | **មាត្រា៣១២** ._ វិសាលភាព<br>គន្លីទី៤ មាតិកាទី២ ជំពូកទី១ | **មាត្រា៣៤០**._ វិសាលភាព<br>មាតិកានេះមានវិសាលភាពចំពោះ.... នៃការគ្រប់គ្រងរួមគ្នាដូចមានចែងក្នុងមាតិកានេះ។<br>គន្លីទី៤ មាតិកាទី៣ ជំពូកទី១ | មានការប្តូរលេខមាត្រា ពីមាត្រា៣១២ ក្នុងកំណែទី១០ មកមាត្រា៣៤០ ក្នុងកំណែ១១ ហើយបន្ថែមខ្លឹមសារលំអិតជាមុន។<br>សូមឱ្យដកឃ្លា "ដីបម្រុងទុករបស់ជនជាតិដើមភាគតិច ឬដីជាលក្ខណៈប្រពៃណីដទៃទៀត" ព្រោះដីនេះ គឺជាដីឯកជនរបស់សហគមន៍ជនជាតិដើមភាគតិច។ |
| | **មាត្រា៣១៣** .សមាសភាគនៃតំបន់ដែលមានសក្តានុពល.....បង្កើតជាតំបន់រួមគ្នា។ | | |
| | **មាត្រា៣១៥** ._ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងរួមគ្នា<br>ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា ក្នុងរយៈពេល ៣ (បី) ឆ្នាំ ក្រោយពេលក្រមនេះចូលជាធរមាន ។ | **មាត្រា៣៤១**. គោលការណ៍..............<br>ក្រោយពេលក្រមនេះ ចូលជាធរមាន។ | មានការពន្យល់ច្បាស់ជាងមុន<br>អាចទទួលយកបាន |

| | | | |
|---|---|---|---|
| | | មាត្រា ៣៤២ ការបន្តយន្តការ តំបន់គ្រប់គ្រងធម្មជាតិដោយផ្អែកលើសហគមន៍ …………………………………………….. ………………………………………….. នៅពេលមានការដាក់បញ្ចូលគ្នា ឬប្តូរពីសហគមន៍តំបន់ការពារធម្មជាតិ…….ត្រូវមានការទទួលស្គាល់ដោយស្វ័យប្រវត្តិតាមរយៈបទដ្ឋានគតិយុទ្ធស្តីពីការគ្រប់គ្រងរួមដោយ ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ | ស្នើសុំឱ្យដូរៈ [នៅពេលដែលសហគមន៍នីមួយបានសម្រេចចិត្តដោយស្មគ្រ័ចិត្តដាក់បញ្ចូលគ្នា ឬប្តូរពីសហគមន៍…………..] |
| | **មាត្រា៣១៤** ._ ការបន្តឋានៈផ្លូវច្បាប់នៃយន្តការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិរបស់សហគមន៍............................ ហើយត្រូវអនុវត្តតាមវិធាន និងបទប្បញ្ញត្តិស្តីពីការគ្រប់គ្រងរួមគ្នា ។ | **មាត្រា៣៤២**??._ ការកាត់បន្ថយការគ្រប់គ្រង................ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ។ | មានការពន្យល់ច្បាស់ជាងមុន អាចទទួលយកបាន |
| | **មាត្រា៣១៦** ._ សិទ្ធិដើម្បីធ្វើការគ្រប់គ្រងរួមគ្នា.................. និងធ្វើការគ្រប់គ្រងរួមគ្នាលើតំបន់ដែលត្រូវធ្វើការគ្រប់គ្រងរួមគ្នា ។ | **មាត្រា៣៤៣**._ ការកាត់បន្ថយការគ្រប់គ្រង................ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ។ | មានការពន្យល់ច្បាស់ជាងមុន អាចទទួលយកបាន |

| | | | |
|---|---|---|---|
| | **មាត្រា៣១៧** ._ ការរៀបចំការគ្រប់គ្រងរួមគ្នា<br>តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច.................ត្រូវស្របតាមបទប្បញ្ញត្តិស្ដីពីប្រព័ន្ធតំបន់ការពារធម្មជាតិនៃក្រមនេះ ។ | **មាត្រា៣៤៤**._ ការកាត់បន្ថយការគ្រប់គ្រង ................ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ។ | មានការពន្យល់ច្បាស់ជាងមុន<br>អាចទទួលយកបាន |
| | **មាត្រា៣១៨** ._ ការគាំទ្រសម្រាប់ការគ្រប់គ្រងរួមគ្នា...................អាចដាក់បញ្ចូលនៅក្នុងលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។ | **មាត្រា៣៤៥** ._ ការគាំទ្រសម្រាប់ការគ្រប់គ្រងរួមគ្នា...................ដើម្បីរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។ | មានការពន្យល់ច្បាស់ជាងមុន<br>អាចទទួលយកបាន |
| | **មាត្រា៣១៩** ._ ការពិនិត្យលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា....................ឯកសារទាំងអស់ដែលទាក់ទងនឹងលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងបាន ។ | **មាត្រា៣៤៦** ._ ការពិនិត្យឡើងវិញលើការរៀបចំគ្រប់គ្រងរួមគ្នា....................ឯកសារអំពីការរៀបចំគ្រប់គ្រងរួមគ្នា ត្រូវផ្សព្វផ្សាយឱ្យសាធារណៈជនអាចស្វែងបាន ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ។ | មានការពន្យល់ច្បាស់ជាងមុន<br>អាចទទួលយកបាន |
| | **មាត្រា៣២០** ._ លិខិតបទដ្ឋានគតិយុត្តស្ដីពីការគ្រប់គ្រងរួមគ្នា...............<br>អាណត្តិនៃអាជ្ញាធរគ្រប់គ្រងរួមគ្នាមានរយៈពេលមិនកំណត់ ។ | **មាត្រា៣៥១** . លិខិតបទដ្ឋានគតិយុត្តស្ដីពីការគ្រប់គ្រងរួមគ្នា............... | ត្រូវគ្នាទៅទៅ មាត្រា៣៥១ ក្នុងកំណែទី១១<br>អាចទទួលយកបាន |

| | | | |
|---|---|---|---|
| | **មាត្រា៣២១** ._ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា.........................និងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងបាន ។ | **មាត្រា៣៤៧** ._ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា............... ត្រូវផ្សព្វផ្សាយឱ្យសាធារណៈជនអាចស្វែងបាន ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ។ | តើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា អាចបន្តបានប៉ុន្មានដង? |
| | **មាត្រា៣៤៨** ._ ការទទួលស្គាល់ស្របច្បាប់ លើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា....................ដែលអាស្រ័យតាម។ | **មាត្រា៣៤៨** ._ ការទទួលស្គាល់ស្របច្បាប់ លើកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា....................ដែលអាស្រ័យតាម។ | អាចទទួលយកបាន |
| | **មាត្រា៣២២** ._ ក្របខ័ណ្ឌនៃការអនុវត្តការគ្រប់គ្រងរួមគ្នា....................និងលទ្ធផលនៃការអនុវត្តការងាររបស់ខ្លួន ។ | **មាត្រា៣៤៩** ._ បទប្បញ្ញត្តិលើអនុត្តន៍ការគ្រប់គ្រងរួមគ្នា.........................ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ។ | សូមបន្ថែមឃ្លា មុនសញ្ញា "។" បញ្ចប់ល្បះ នូវឃ្លា "ក្នុងលក្ខខ័ណ្ឌដែលគណៈកម្មការគ្រប់គ្រងរួមគ្នា ទទួលបានការលើកកម្ពស់ និងគាំទ្រពីស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ ឬស្ថាប័នពាក់ព័ន្ធនានា។ |
| | **មាត្រា៣២៣** ._ ការលើកកម្ពស់ និងការគាំទ្រការគ្រប់គ្រងរួមគ្នា.................... បែងចែកសិទ្ធិអំណាចជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឬរដ្ឋបាលថ្នាក់ក្រោមជាតិ ។ | **មាត្រា៣៥២** ._ ការលើកកម្ពស់ និងការគាំទ្រដល់ការគ្រប់គ្រងរួមគ្នា.......... | អាចទទួលយកបាន |
| | **មាត្រា៣២៤** ._ ការហាមឃាត់ចំពោះសកម្មភាព..............................ដែលផ្ទុយនឹងកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ដែលទទួលបានការឯកភាពឡើយ ។ | **មាត្រា៣៥៣** ._ សកម្មភាពដែលបានហាមឃាត់.... | អាចទទួលយកបាន |

| | | | |
|---|---|---|---|
| | **មាត្រា៣២៥** ._ ការលុបចោលកិច្ចព្រមព្រៀងស្តីការគ្រប់គ្រងរួមគ្នា................... មានសិទ្ធិធ្វើបណ្តឹងតវ៉ា ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។ | **មាត្រា៣៥០** ._ ការបញ្ចប់កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា........... | តើត្រូវមាននិតិវិធីយ៉ាងដូចម្តេច ប្រសិនបើសហគមន៍ចង់បញ្ចប់កិច្ចសន្យាវិញ? |
| | **មាត្រា៣២៦** ._ អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា...................ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។ | **មាត្រា៣៥៤** ._ អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា.............. ដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ។ | អាចទទួលយកបាន |
| | **មាត្រា៣២៧** ._ ខ្លឹមសារនៃអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា..............ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ ។ | **មាត្រា៣៥៥** ._ ខ្លឹមសារនៃអាណត្តិកាន់កាប់...................ត្រូវអនុវត្តតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាននៃក្រមនេះ ។ | អាចទទួលយកបាន |
| | **មាត្រា៣២៨** ._ រយៈពេលនៃអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា<br>រយៈពេលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា មានសុពលដូចគ្នាទៅនឹងរយៈពេលនៃតំបន់គ្រប់គ្រងរួមគ្នា ។ | **មាត្រា៣៥៦** ._ រយៈពេលនៃអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា<br>រយៈពេលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា មានសុពលដូចគ្នាទៅនឹងរយៈពេលនៃតំបន់គ្រប់គ្រងរួមគ្នា ។ | អាចទទួលយកបាន |
| | **មាត្រា៣២៩** ._ ការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់ | **មាត្រា៣៥៧** ._ ការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់ | អាចទទួលយកបាន |

| | | | |
|---|---|---|---|
| | គ្រប់គ្រងរួមគ្នា..................មិននាំឱ្យមានការលុបចោលអាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នានោះទេ ។ | គ្រប់គ្រងរួមគ្នា................ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នានោះទេ ។ | |
| | **មាត្រា៣៣០** ._ សិទ្ធិបន្ថែម<br>អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា ត្រូវជាសិទ្ធិបន្ថែមលើសិទ្ធិដទៃទៀតដែលសហគមន៍ជនជាតិដើមភាគតិចទទួលបាន ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ | **មាត្រា៣៥៨**._ សិទ្ធិបន្ថែម<br>អាណត្តិកាន់កាប់ និងប្រើប្រាស់ដីរដ្ឋនៃតំបន់គ្រប់គ្រងរួមគ្នា......................តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ | អាចទទួលយកបាន |
| | **មាត្រា៣៣១** ._ ការរៀបចំសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ.............ក្នុងពេលបច្ចុប្បន្ន ឬក្នុងពេលអនាគត ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានឡើយ ។ | | មិនមាននៅក្នុងកំណែទី១១នៃគន្ថីទី៤ "ការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ" ទៀតទេ |
| | **មាត្រា៣៣២** ._ មូលនិធិបរធនបាលកិច្ចបរិស្ថានសម្រាប់ការគ្រប់គ្រងរួមគ្នា | | បានដាក់បញ្ចូលនៅក្នុងគន្ថីទី៨ មាតិតាទី១ ជំពូកទី២ មាត្រា៩៧៤ ដល់៩៧៦។ |
| | **មាត្រា៣៣៣** ._ ការលើកលែងពន្ធ និងការប្រើប្រាស់ចំណូល ថ្លៃសេវា ឬការបរិច្ចាគ | | បានដាក់បញ្ចូលនៅក្នុងគន្ថីទី៨ មាតិតាទី១ ជំពូកទី២ មាត្រា៩៦៦ ដល់ ៩៧០។ |

| | |
|---|---|
| | <u>មតិយោបល់បន្ថែម</u><br>**មាត្រា៣៥៩.**_ សិទ្ធិប្រើប្រាស់ដីសមូហភាពក្នុងក្របខ័ណ្ឌះសូមឱ្យដកដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចចេញពីទីតាំងនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា។ ព្រោះដីនេះ គឺជាដីឯកជនរបស់សហគមន៍ជនជាតិដើមភាគតិច ដែលមានសិទ្ធិផ្ទេរទៅឱ្យកូនចៅជំនាន់ក្រោយ។<br><br>**មាត្រា៣៦០.**_ សិទ្ធិ និងការដាក់កំហិតះ សូមឱ្យដកដីសមូហភាពសហគមន៍ជនជាតិដើមភាគតិចចេញពីទីតាំងនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា។ ព្រោះដីនេះ គឺជាដីឯកជនរបស់សហគមន៍ជនជាតិដើមភាគតិច ដែលមានសិទ្ធិផ្ទេរទៅឱ្យកូនចៅជំនាន់ក្រោយ។<br><br>**មាត្រា៣៦២.**_ ការដកហូតសិទ្ធិប្រើប្រាស់ដីះក្នុងខ្លឹមសារនៃមាត្រានេះ សិទ្ធិរស់នៅ សិទ្ធិដកហូតអនុផលព្រៃឈើ និងសិទ្ធិអភិរក្ស របស់សហគមន៍ គួរតែរក្សាទុក បើទោះបីអាណត្តិរបស់សហគមន៍ត្រូវបានដកហូត។<br><br>**មាត្រា៣៦៣.**_ សិទ្ធិបន្ថែមលើសិទ្ធិប្រើប្រាស់ដី ក្នុងក្របខ័ណ្ឌគ្រប់គ្រងរួមគ្នាះសិទ្ធិដីសមូហភាពសហគមន៍ជនជាតិដើមភាគតិច គឺជាសិទ្ធិដែលមានស្រាប់ដែលមានចែងក្នុងច្បាប់ភូមិបាល។<br><br>**មាត្រា៣៦៤.**_ ផលប៉ះពាល់លើការកំណត់តំបន់ការពារធម្មជាតិះគួរប្តូរទៅជា "ផលប៉ះពាល់លើការកំណត់សិទ្ធិប្រើប្រាស់រួមរបស់ជនជាតិដើមភាគតិច" |

# **មតិយោបល់របស់អង្គការសង្គមស៊ីវិល**

## **លើសេចក្តីព្រាងទី១១ នៃក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា**

## **ប្រធានបទ ៖ គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានពត៌មានគ្រប់ជ្រុងជ្រោយ**

| លរ<br>NO | មតិយោបល់/សំណូមពររបស់<br>សង្គមស៊ីវិល លើសេចក្តីព្រាងទី១០ | គន្លី/មាតិកា/ជំពូក | មតិយោបល់/សំណូមពរ/កំណែប្រែថ្មី<br>លើសេចក្តីព្រាងទី១១ |
|---|---|---|---|
| | **មាត្រា១៨** ជំពូក ២. គោលការណ៍ទូទៅ........<br>• ក្នុងមាត្រា ១៨ ក្នុងសេចក្តីព្រាងទី ១១ (ទំព័រ ៥). _គោលការណ៍…….សហគមន៍ជនជាតិភាកតិច………ធនធានធម្មជាតិត្រូវទទួល……..។ | ជំពូក ២. គោលការណ៍ទូទៅ........<br>• ក្នុងមាត្រា ១៨ ក្នុងសេចក្តីព្រាងទី ១១ (ទំព័រ ៥). _គោលការណ៍…….សហគមន៍ជនជាតិភាកតិច………ធនធានធម្មជាតិត្រូវទទួល……..។ | មាត្រា១៨ បានដាក់បញ្ចូល តែសូមបន្ថែមខ្លឹមសារៈ<br>• សិទ្ធិ សេដ្ឋកិច្ច សង្គម និង វប្បធម៌ របស់ជនជាតិដើមភាគតិចក្នុងការចូលរួមតាមដំណាក់កាលខាងក្រោមៈ<br>១) ដំណាក់កាលសិក្សាស្រាវជ្រាវបឋម<br>២) ដំណាក់កាលរៀបចំគម្រោង<br>៣) ដំណាក់កាលអនុវត្តគម្រោង និង<br>៤)ដំណាក់កាលបញ្ចប់គម្រោង។ |
| | **មាត្រា២៣**_ អ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបានព័ត៌មានគ្រប់គ្រាន់ ។ ការផ្តល់ព័ត៌មានទាំងនោះត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាន និងវប្បធម៌របស់អ្នកពាក់ព័ន្ធ។<br>៤- កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ: ត្រូវយកចិត្តទុកដាក់អំពីតម្រូវការ កង្វល់ និងតម្លៃរបស់អ្នកពាក់ព័ន្ធ ។ | មាត្រា២៣នៃសេចក្តីព្រាងទី ១០បានដាក់បញ្ចូលខ្លឹមសារទៅមាត្រា២៤ ជំពូកទី១ ក្នុងសេចក្តីព្រាងលើកទី១១ (ទំព័រ ៨)<br>_ លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ........ក្រសួង ស្ថាប័នពាក់ព័ន្ធ...... | អាចទទួលយកបាន |

| | | | |
|---|---|---|---|
| | ៦- កម្រិតនៃការចូលរួមជាសាធារណៈ ត្រូវធ្វើឡើងស្របតាមសិទ្ធិនៃការចូលរួមពេញលេញនិងមានប្រសិទ្ធភាព ។<br><br>៧- ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានភាពបត់បែន និងអាចកែសម្រួលបាន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកដែលសមហេតុផលរបស់អ្នកពាក់ព័ន្ធ ។ | | |
| | មាត្រា២៥ ._ ការពិគ្រោះយោបល់របស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច<br><br>ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិច លើគោលនយោបាយ ផែនការ ឬ កម្មវិធី ដែលរងផលប៉ះពាល់ដោយផ្ទាល់ និងប្រយោល ចំពោះ ដីធ្លី និងធនធាននានា របស់ជនជាតិដើមភាគតិច។ | មាត្រា២៥នៃសេចក្តីព្រាងទី ១០បានដាក់បញ្ចូលខ្លឹមសារទៅមាត្រា២៦ ជំពូក ទី ២ក្នុងសេចក្តីព្រាងលើកទី១១ (ទំព័រ ៩)_ ការពិគ្រោះ...ក្រសួងស្ថប័នពាក់ព័ន្ធ…….ជនជាតិដើមភាគតិច។ | អាចទទួលយកបាន |
| | មាត្រា២៨ ជំពូក ទី ២ក្នុងសេចក្តីព្រាងលើកទី១១ (ទំព័រ ៩)៖ ការចូលរួមរបស់ជនជាតិដើមភាគតិច……ទទួលរងផលប៉ះពាល់……បរិស្ថាននិងធនធានធម្មជាតិ។ | មាត្រា២៦នៃសេចក្តីព្រាងទី ១០បានដាក់បញ្ចូលខ្លឹមសារទៅមាត្រា២៨ ជំពូក ទី ២ក្នុងសេចក្តីព្រាងលើកទី១១ (ទំព័រ ៩)_ការចូលរួមរបស់ជនជាតិដើមភាគតិច……ទទួលរងផលប៉ះពាល់……បរិស្ថាននិងធនធានធម្មជាតិ។ | **មាត្រា២៦៖**<br>មាត្រានេះបានប្តូរទៅមាត្រា ២៧ ក្នុងពង្រាងទី១០ ស្នើឱ្យពិនិត្យមតិយោបល់របស់សង្គមស៊ីវិល លើពង្រាងទី ៩.១<br>**មាត្រា២៧** ._ ការចូលរួមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច |

| | | | |
|---|---|---|---|
| | | | ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្ដល់ឱកាសឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ពីសេចក្ដីសម្រេចទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ។<br>ការចូលរួមត្រូវធ្វើឡើងដោយគ្មានការគំរាមកំហែង ការបោកបញ្ឆោត ឬការបង្ខិតបង្ខំ និងត្រូវផ្ដល់ឱកាសឱ្យមានការចូលរួមឱ្យបានទាន់ពេលវេលា ហើយអ្នកចូលរួមត្រូវទទួលបានការជូនដំណឹងពេញលេញអំពីព័ត៌មានទាំងអស់ក្នុងទម្រង់ និងភាសាដែលសមស្រប។ |
| | **មាត្រា ២៦** ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ មិនត្រូវឯកភាពលើផែនការ កម្មវិធី ឬ សំណើរគម្រោង ដែលអាចប៉ះពាល់ផ្ទាល់ និង ដោយប្រយោលដល់ ប្រជាពលរដ្ឋខ្មែរ ជាពិសេសសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមជាមុនដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនជាតិដើមភាគតិចបានឡើយ ។ ការយល់ព្រមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាតនៃសហគមន៍មូលដ្ឋាន និងជនជាតិដើម | មាត្រា២៧នៃសេចក្ដីព្រាងទី ១០បានដាក់បញ្ចូលខ្លឹមសារទៅមាត្រា២៧ ជំពូក ទី២ ក្នុងសេចក្ដីព្រាងលើកទី១១ (ទំព័រ ៩)៖ ការយល់ព្រម.....ក្រសួង ស្ថាប័នមានសមត្ថកិច្ច....គម្រោងស្នើសុំ ឬការធ្វើសេចក្ដីសម្រេចនេះ។ | សូមប្ដូរខ្លឹមសារពីមតិ ភាគច្រើនដាច់ខាត ទៅជា ការព្រមព្រៀងដោយសមូហភាព។<br>(ផ្អែកលើស្មារតីច្បាប់ភូមិបាល និងគោលនយោបាយពាក់ព័ន្ធនិងជនជាតិដើមភាគតិច)។ |

| | | | |
|---|---|---|---|
| | ភាគតិច ដែលអាចទទួលរងផលប៉ះពាល់ពីគម្រោងស្នើសុំ ឬការធ្វើសេចក្តីសម្រេចនេះ ។<br><br>ចំណែកផែនការ កម្មវិធី ឬគម្រោងដែលបាននិងកំពុងអនុវត្តហើយមានការប៉ះពាល់ដល់ជនជាតិដើមភាគតិច ត្រូវតែរៀបចំយន្តការពិគ្រោះពិភាក្សា និងដោះស្រាយឡើងវិញជាមួយពួកគាត់សំដៅទទួលបានពត៌មានពេញលេញ និងយល់ព្រមដោយសេរីពីការអភិវឌ្ឍទាំងនេះ។<br><br>គោលការណ៍នៃការយល់ព្រមជាមុនដោយសេរី និងបន្ទាប់ពីទទួលបានព័តិមានគ្រប់ជ្រុងជ្រោយ ត្រូវបានគេយកទៅអនុវត្តចំពោះគ្រប់គម្រោងអភិវឌ្ឍន៍ដែលកំពុងដំណើរការនិងស្នើឡើង។ | | |
| | **មាត្រា៣០** ._ ការផ្លាស់ទីលំនៅថ្មីដោយមិនស្ម័គ្រចិត្តក្នុងករណីដែលតម្រូវឱ្យមានការផ្លាស់ទីលំនៅថ្មីដោយមិនស្មគ្រ័ចិត្តសម្រាប់គម្រោងស្នើសុំ នោះម្ចាស់គម្រោង ឬក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវផ្តល់ឱកាស និងពេលវេលាគ្រប់គ្រាន់ឱ្យសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ចូលរួមក្នុងការពិចារណា និងសម្រេចចិត្តអំពីជម្រើសផ្សេងៗពាក់ព័ន្ធនឹងសិទ្ធិសង្គម វប្បធម៌ និងសេដ្ឋកិច្ច ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវការគំរាម | ជំពូក ទី ៣ មាត្រា ៣១ ខ្លឹមសា ការតាំងទីលំនៅថ្មីដោយមិនមានការស្ម័គ្រចិត្ត | ខ្លឹមសារនេះបានដាក់បញ្ចូលក្នុង មាត្រា ៣១ និង ៣២<br>• ស្នើអោយមានគណៈកម្មការជំនាញ ឯករាជ្យដែលមានសមាសភាពចម្រុះរួមមាន<br>○ អង្គការសង្គមស៊ីវិល<br>○ តំណាងសហគមន៍<br>○ សហគមន៍ជនជាតិដើមភាគតិច<br>○ តំណាងរដ្ឋាភិបាល<br>○ តំណាងដៃគូអភិវឌ្ឍន៍<br>○ មេធាវី ចៅក្រម<br>○ ស្ថាប័នឯករាជ្យដែលមានជំនាញ និងស្ថាប័នពាក់ព័ន្ធ។ |

| | | | |
|---|---|---|---|
| | កំហែង ការបោកបញ្ឆោត ឬការបង្ខិតបង្ខំពីការផ្លាស់ប្តូរទីលំនៅថ្មី។<br>ករណីដែលតម្រូវឲ្យមានការផ្លាស់ប្តូរទីលំនៅថ្មី ដោយមិនស្ម័គ្រចិត្ត មានលក្ខខណ្ឌដូចជា ការលេចធ្លាយឧស្ម័នពុល តំបន់អសន្តិសុខ តំបន់មានគ្រោះមហន្តរាយធ្ងន់ធ្ងរ ជាដើម។ | | ក្នុងករណី ពាក់ព័ន្ធនឹងការរំលោភសិទ្ធិសង្គម វប្បធម៌ និងសេដ្ឋកិច្ច ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវការគំរាមកំហែង ការបោកបញ្ឆោត ឬការបង្ខិតបង្ខំពីការផ្លាស់ប្តូរទីលំនៅថ្មី ដែលតម្រូវឲ្យមានការផ្លាស់ប្តូរទីលំនៅថ្មី ដោយមិនមានការស្ម័គ្រចិត្ត។ |
| | <u>**មតិយោបល់បន្ថែម**</u><br><br>**មាត្រា ១២៦** នេះត្រូវបានលុបចោល សូមធ្វើការបកស្រាយ<br>**មាត្រា ១២៧៖** មាត្រានេះត្រូវបានលុបចោល សូមធ្វើការបកស្រាយ | | |

**<u>មតិយោបល់របស់អង្គការសង្គមស៊ីវិល</u>**

**<u>លើសេចក្តីព្រាងទី១១ នៃក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា</u>**

**ប្រធានបទ ៖ ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន**

| លរ | មតិយោបល់/សំណូមពររបស់សង្គមស៊ីវិល លើសេចក្តីព្រាងទី១០ | គន្លឹ/មាតិកា/ជំពូក | មតិយោបល់/សំណូមពរ/កំណែប្រែថ្មី លើសេចក្តីព្រាងទី១១ |
|---|---|---|---|
| ១ | **មាត្រា៥៖** គោលការណ៍នៃការចូលរួមជាសាធារណៈ<br>បុគ្គលទាំងឡាយណា ដែលអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ ប្រយោល <u>ឬចាប់អារម្មណ៍</u>ក្នុងការសម្រេចចិត្តណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួម<u>ពេញលេញ</u>ក្នុងការផ្តល់មតិយោបល់ទាន់ពេលវេលា និងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលធ្វើសេចក្តីសម្រេចចិត្តនោះ ត្រូវធ្វើឡើង តាមរយៈដំណើរការមួយប្រកបដោយតម្លាភាព ការចូលរួម និងគណនេយ្យភាព។ | មាត្រា៦៖ គោលការណ៍នៃការចូលរួមជាសាធារណៈ<br>រូបវន្តបុគ្គល ឬនីតិបុគ្គលដែលអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោល ដោយសារការធ្វើសេចក្តីសម្រេចណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ឲ្យទាន់ពេលវេលា និងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលធ្វើសេចក្តីសម្រេច តាមរយៈដំណើរការចូលរួមពីគ្រប់បុគ្គលពាក់ព័ន្ធ ដោយតម្លាភាព និងគណនេយ្យភាព។ | កំណត់ចំណាំ៖ មាត្រា៦ សេចក្តីព្រាងទី១១ បានកែសម្រួលមានអត្ថន័យប្រសើរជាងមុន (ប្តូរពីបុគ្គលទាំងឡាយណាមករូបវន្តបុគ្គល ឬនីតិបុគ្គលវិញ) និងបានដាក់បញ្ចូលសេចក្តីស្នើមួយចំនួនរបស់អង្គការសង្គមស៊ីវិល។ |
| ២ | **មាត្រា៧៖** គោលការណ៍នៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធិភាពបុគ្គលគ្រប់រូប មានសិទ្ធិទទួលបានដំណោះស្រាយ | **មាត្រា៨៖** គោលការណ៍នៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធិភាព | ទទួលយកបាន |

| | | | |
|---|---|---|---|
| | ផ្នែករដ្ឋបាល និងផ្នែកតុលាការ ឬក៏មធ្យោបាយសមស្របដទៃទៀត ដែលពាក់ព័ន្ធទៅនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ប្រកដោយយុត្តិធម៌ និងប្រសិទ្ធិភាព។<br>យន្តការដោះស្រាយវិវាទ ប្រកបដោយប្រសិទ្ធិភាព និងមិនលម្អៀង ត្រូវរៀបចំឡើង ដើម្បីលើកកម្ពស់ការអនុវត្តច្បាប់ និងផ្តន្ទាទោសចំពោះបុគ្គលគ្រប់រូប ដែលបង្កការខូចខាតដល់បរិស្ថាន និងធនធានធម្មជាតិ។ | រូបវន្តបុគ្គល ឬនីតិបុគ្គលទាំងអស់ មានសិទ្ធិទទួលបាននីតិវិធីរដ្ឋបាល និងតុលាការ ឬមធ្យោបាយសមស្របដទៃទៀត ដើម្បីសម្រេចបាននូវការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធិភាព។<br>យន្តការដោះស្រាយវិវាទ ប្រកបដោយប្រសិទ្ធិភាព និងមិនលម្អៀង ត្រូវរៀបចំឡើង ដើម្បីលើកកម្ពស់ការអនុវត្តច្បាប់ និងផ្តន្ទាទោសចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលបង្កការខូចខាតដល់បរិស្ថាន ធនធានធម្មជាតិ និងសង្គម និងផ្តល់សំណងសម្រាប់ការខូចខាតទាំងនោះ។ | |
| ៣ | **មាត្រា១៨** គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់សហគមន៍ជនជាតិដើមភាគតិច<br>សកម្មភាព ឬគម្រោងដែលស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀត ជាពិសេស ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិច នៅគ្រប់ | **មាត្រា១៨** គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់សហគមន៍ជនជាតិដើមភាគតិច<br>សកម្មភាព ឬគម្រោងដែលស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀត របស់ជនជាតិដើមភាគតិច ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិច។ | ស្នើសុំពិចារណាឡើងវិញដូចខាងក្រោម៖<br>**មាត្រា១៨** គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់សហគមន៍ជនជាតិដើមភាគតិច<br>សកម្មភាព ឬគម្រោងដែលស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀត របស់ជនជាតិដើមភាគតិច ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានពត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិច នៅគ្រប់ដំណាក់កាលនៃ |

| | | | |
|---|---|---|---|
| | ដំណាក់កាលនៃគម្រោងដែលស្នើឡើង រួមមាន ១) ដំណាក់កាលសិក្សាស្រាវជ្រាវបឋម ២) ដំណាក់កាលរៀបចំគម្រោង ៣)ដំណាក់កាលរៀបចំគម្រោង និង ៤)ដំណាក់កាលបញ្ចប់គម្រោង។ | | គម្រោងដែលស្នើឡើង រួមមាន ១) ដំណាក់កាលសិក្សាស្រាវជ្រាវបឋម ២)ដំណាក់កាលរៀបចំគម្រោង ៣)ដំណាក់ការអនុវត្តគម្រោង(ចំណុចទី២ ទី៣ ដូចគ្នា) និង ៤)ដំណាក់កាលបញ្ចប់គម្រោង។ |
| ៤ | **មាត្រា២១** សិទ្ធិក្នុងការចូលរួមជាសាធារណៈ:<br>បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមជាសាធារណៈ និងអាចអនុវត្តសិទ្ធិរបស់ខ្លួន ដូចខាងក្រោម៖<br>១. រាយការណ៍ ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការធ្វើសេចក្តីសម្រេចណាមួយ ដែលអាច នឹងមានផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ។<br>២. លើកឡើងនូវសំណួរ ស្នើឲ្យមានការបកស្រាយ ធ្វើការតវ៉ា និងចូលរួមពិភាក្សា អំពីសកម្មភាព ឬសេចក្តីសម្រេចណាមួយ ដែលអាចបង្កឲ្យមានផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ។<br>ទទួលបានព័ត៌មាន និងមានការចូលរួមទាន់ពេលវេលាក្នុងការពិភាក្សា និងផ្តល់ | **មាត្រា២២** សិទ្ធិក្នុងការចូលរួមជាសាធារណៈ:<br>រូបវន្តបុគ្គល ឬនីតិបុគ្គល មានសិទ្ធិក្នុងការចូលរួមជាសាធារណៈ តាមរយៈសកម្មភាពដូចខាងក្រោម៖<br>១. រាយការណ៍ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការធ្វើសេចក្តីសម្រេចណាមួយ ដែលអាចបង្កឲ្យមានផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ។<br>២. លើកឡើងនូវសំណួរ ស្នើឲ្យមានការបកស្រាយ ធ្វើការតវ៉ា និងចូលរួមពិភាក្សា អំពីសកម្មភាព ឬសេចក្តីសម្រេចណាមួយ ដែលអាចបង្កឲ្យមានផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ។<br>៣. ដាក់ពាក្យបណ្តឹង ឬប្តឹងតវ៉ានឹងសកម្មភាព ឬសេចក្តីសម្រេចស្របតាមយន្តការ | សំណើរដូចខាងក្រោម៖<br>**មាត្រា២២** សិទ្ធិក្នុងការចូលរួមជាសាធារណៈ:<br>រូបវន្តបុគ្គល ឬនីតិបុគ្គល មានសិទ្ធិក្នុងការចូលរួមជាសាធារណៈ តាមរយៈសកម្មភាពដូចខាងក្រោម៖<br>១. រាយការណ៍ ផ្ទាល់មាត់ ឬលាយលក្ខណ៍ អក្សរ ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការធ្វើសេចក្តីសម្រេចណាមួយ ដែលអាចបង្កឲ្យមានផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ។<br>២. លើកឡើងនូវសំណួរ ស្នើឲ្យមានការ បកស្រាយ ធ្វើការតវ៉ា និងចូលរួមពិភាក្សា អំពីសកម្មភាព ឬសេចក្តីសម្រេចណាមួយ ដែលអាចបង្កឲ្យមានផលប៉ះពាល់បរិស្ថាន និងធនធានធម្មជាតិ។<br>ទទួលបានព័ត៌មាន និងមានការចូលរួមទាន់ពេលវេលាក្នុងការពិភាក្សា និងផ្តល់យោបល់សម្រាប់សេចក្តីសម្រេចណាមួយ ដែលអាចបង្កឲ្យ |

| | | | |
|---|---|---|---|
| | យោបល់ សម្រាប់សេចក្តីសម្រេចណាមួយ ដែលអាចបង្កឲ្យមានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ។<br>៣. ដាក់ពាក្យបណ្តឹង ឬប្តឹងតវ៉ានឹងសកម្មភាព ឬសេចក្តីសម្រេចស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុង គន្ថីទី៩ នៃក្រមនេះ។ | ដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុង គន្ថីទី៩ នៃក្រមនេះ។ | មានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ។ (ចំណុចនេះមិនបានដាក់បញ្ចូលហើយចំណុចនេះត្រូវស្ថិតនៅក្នុងចំណុចទី២)<br>៣. ដាក់ពាក្យបណ្តឹង ឬប្តឹងតវ៉ានឹងសកម្មភាព ឬសេចក្តីសម្រេចស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុង គន្ថីទី៩ នៃក្រមនេះ។ |
| ៥ | **មាត្រា២៤** លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ:<br>មុននឹងធ្វើសេចក្តីសម្រេច ឬឯកភាពលើបញ្ហាណាមួយពាក់ព័ន្ធនឹងក្រមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងម្ចាស់គម្រោងទាំងអស់ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ ដូចខាងក្រោម៖<br>១. ផែនការសម្រាប់ការចូលរួមជាសាធារណៈ ត្រូវកំណត់ និងរៀបចំឡើង ដើម្បីធានាថា អ្នកពាក់ព័ន្ធ អ្នកទទួលរងផលប៉ះពាល់ និងភាគីដែលមានចំណាប់អារម្មណ៍ ចូលរួមពេញលេញ និងសកម្ម។<br>២. អ្នកពាក់ព័ន្ធត្រូវទទួលបានការជូនដំណឹង និងពេលវេលាគ្រប់គ្រាន់ សម្រាប់ចូល | **មាត្រា២៤** លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ:<br>មុននឹងធ្វើសេចក្តីសម្រេច ឬឯកភាពលើបញ្ហាណាមួយពាក់ព័ន្ធនឹងក្រមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងម្ចាស់គម្រោងទាំងអស់ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ ដូចខាងក្រោម៖<br>១. អ្នកពាក់ព័ន្ធត្រូវទទួលបានការជូនដំណឹង និងពេលវេលាគ្រប់គ្រាន់ សម្រាប់ចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធ។<br>២. អ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបានព័ត៌មានចាំបាច់។ ការផ្តល់ព័ត៌មានទាំង នេះត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាន និងវប្បធម៌របស់អ្នកពាក់ព័ន្ធ។ | ស្នើពិចារណាសាជាថ្មីចំពោះសេចក្តីស្នើរបស់អង្គការសង្គមស៊ីវិល ដែលមានដូចខាងក្រោម៖<br>**មាត្រា២៤** លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ:<br>មុននឹងធ្វើសេចក្តីសម្រេច ឬឯកភាពលើបញ្ហាណាមួយពាក់ព័ន្ធនឹងក្រមនេះក្រសួង ស្ថាប័ន ពាក់ព័ន្ធ និងម្ចាស់គម្រោងទាំងអស់ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ: ដូចខាងក្រោម៖<br>១. ផែនការសម្រាប់ការចូលរួមជាសាធារណៈ: ត្រូវកំណត់ និងរៀបចំឡើង ដើម្បីធានាថា អ្នកពាក់ព័ន្ធ អ្នកទទួលរងផលប៉ះពាល់ និងភាគីដែលមានចំណាប់អារម្មណ៍ ចូលរួមពេញលេញ និងសកម្ម។ (មិនបានដាក់បញ្ចូល) |

| | | | |
|---|---|---|---|
| | រួមនៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចដែលពាក់ព័ន្ធ។<br>៣. អ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបានព័ត៌មានចាំបាច់។ ការផ្ដល់ព័ត៌មានទាំង នេះត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាន និងវប្បធម៌របស់អ្នកពាក់ព័ន្ធ។<br>៤. ចំណេះដឹងខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងចំណេះដឹងលក្ខណៈប្រពៃណីនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចត្រូវយកជាមូលដ្ឋានក្នុងការបង្កើតគម្រោង ផែនការ សកម្មភាព និងការធ្វើសេចក្ដីសម្រេច។<br>៥. កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវយកចិត្តទុកដាក់អំពីតម្រូវការ និងតម្លៃរបស់អ្នកពាក់ព័ន្ធ។<br>៦. អ្នកពាក់ព័ន្ធ ត្រូវទទួលបានពេលវេលាសមស្រប និងត្រឹមត្រូវ ដើម្បីធ្វើការវាយតម្លៃ និងឆ្លើយតបចំពោះព័ត៌មានទាក់ទងនឹងគម្រោងស្នើសុំសកម្មភាព ផែនការ ឬសេចក្ដីសម្រេចណាមួយ។ | ៣. ចំណេះដឹងខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងចំណេះដឹងលក្ខណៈប្រពៃណីនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចត្រូវយកជាមូលដ្ឋានក្នុងការបង្កើតគម្រោង ផែនការសកម្មភាព និងការធ្វើសេចក្ដីសម្រេច។<br>៤. កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវយកចិត្តទុកដាក់អំពីតម្រូវការ និងតម្លៃរបស់អ្នកពាក់ព័ន្ធ។<br>៥. អ្នកពាក់ព័ន្ធ ត្រូវទទួលបានពេលវេលាសមស្រប និងត្រឹមត្រូវ ដើម្បីធ្វើការវាយតម្លៃ និងឆ្លើយតបចំពោះព័ត៌មានទាក់ទងនឹងគម្រោងស្នើសុំសកម្មភាព ផែនការ ឬសេចក្ដីសម្រេចណាមួយ។<br>៦. កម្រិតនៃការចូលរួមជាសាធារណៈ ត្រូវស្របតាមកម្រិតនៃការចាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។<br>៧. ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានភាពបត់បែន និងអាចកែសម្រួលបាន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកដែលសមហេតុផលរបស់អ្នកពាក់ព័ន្ធ។<br>៨. កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានលក្ខណៈបត់បែន និងអាចសម្រប | ២. អ្នកពាក់ព័ន្ធត្រូវទទួលបានការជូនដំណឹង និងពេលវេលាគ្រប់គ្រាន់ សម្រាប់ចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចដែលពាក់ព័ន្ធ។<br>៣. អ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបានព័ត៌មានចាំបាច់។ ការផ្ដល់ព័ត៌មានទាំង នេះត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាន និងវប្បធម៌របស់អ្នកពាក់ព័ន្ធ។<br>៤. ចំណេះដឹងខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងចំណេះដឹងលក្ខណៈប្រពៃណីនៃសហគមន៍ មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវយកជាមូលដ្ឋានក្នុងការបង្កើតគម្រោង ផែនការ សកម្មភាព និងការធ្វើសេចក្ដីសម្រេច។<br>៥. កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវយកចិត្តទុកដាក់អំពីតម្រូវការ និងតម្លៃរបស់អ្នកពាក់ព័ន្ធ។<br>៦. អ្នកពាក់ព័ន្ធ ត្រូវទទួលបានពេលវេលាសមស្រប និងត្រឹមត្រូវ ដើម្បីធ្វើការវាយតម្លៃ និងឆ្លើយតបចំពោះព័ត៌មានទាក់ទងនឹងគម្រោងស្នើសុំសកម្មភាព ផែនការ ឬសេចក្ដីសម្រេចណាមួយ។<br>៧. កម្រិតនៃការចូលរួមជាសាធារណៈ ត្រូវស្របតាមកម្រិតនៃការចាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។ |

| | | | |
|---|---|---|---|
| | ៧. កម្រិតនៃការចូលរួមជាសាធារណៈ ត្រូវស្របតាមកម្រិតនៃការចាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។<br>~~៨. ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានភាពបត់បែន និងអាចកែសម្រួលបាន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកដែលសមហេតុផលរបស់អ្នកពាក់ព័ន្ធ។~~ (ចំណុចនេះ គួរតែលុបចេញ ការដែលបញ្ជាក់ថា មានការបត់បែននោះ ហាក់ដូចជា ពុំមានន័យក្នុងផ្លូវច្បាប់ ឬអាចបើកឲ្យមានការគិត និងធ្វើផ្សេងទៅវិញ)។<br>៩. គ្រប់មតិយោបល់របស់សាធារណជន ត្រូវទទួលបានការពិចារណានៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច។ ការទទួលយក ឬបដិសេធចំពោះមតិយោបល់ខាងលើនេះ ត្រូវបញ្ជាក់ហេតុផលសមរម្យ។<br>១០. រាល់ព័ត៌មាន និងលទ្ធផលនៃកិច្ចដំណើរការចូលរួមជាសាធារណៈ ត្រូវផ្សព្វផ្សាយជាសាធារណៈ ស្របទៅតាមកម្រិត និងការរំពឹងទុករបស់អ្នកពាក់ព័ន្ធ។<br>១១. រាល់គម្រោងអភិវឌ្ឍ និងផែនការវិនិយោគបាន និងកំពុងអនុវត្ត ដោយពុំមានការចូលរួមជាសាធារណៈ ឬមិនបានពេញលេញ ត្រូវផ្អាកជាបណ្តោះអាសន្ន និងត្រូវរៀបចំ | សម្រួលបាន ស្របតាមការរំពឹងទុករបស់អ្នកពាក់ព័ន្ធ។<br>៩. គ្រប់មតិយោបល់របស់សាធារណជន ត្រូវទទួលបានការពិចារណានៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច។ ការទទួលយក ឬបដិសេធចំពោះមតិយោបល់ខាងលើនេះ ត្រូវបញ្ជាក់ហេតុផលសមរម្យ។ | ៨. ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានភាពបត់បែន និងអាចកែសម្រួលបាន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកដែលសមហេតុផលរបស់អ្នកពាក់ព័ន្ធ។ (ចំណុចនេះ គួរតែលុបចេញ ការដែលបញ្ជាក់ថា មានការបត់បែននោះ ហាក់ដូចជា ពុំមានន័យក្នុងផ្លូវច្បាប់ ឬអាចបើកឲ្យមានការគិត និងធ្វើផ្សេងទៅវិញ)។<br>៩. គ្រប់មតិយោបល់របស់សាធារណជនត្រូវទទួលបានការពិចារណានៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច។ ការទទួលយក ឬបដិសេធចំពោះមតិយោបល់ខាងលើនេះ ត្រូវបញ្ជាក់ហេតុផលសមរម្យ។<br>១០. រាល់ព័ត៌មាន និងលទ្ធផលនៃកិច្ចដំណើរការចូលរួមជាសាធារណៈ ត្រូវផ្សព្វផ្សាយជាសាធារណៈ ស្របទៅតាមកម្រិត និងការរំពឹងទុករបស់អ្នកពាក់ព័ន្ធ។<br>១១. រាល់គម្រោងអភិវឌ្ឍន៍ និងផែនការវិនិយោគបាន និងកំពុងអនុវត្តន៍ ដោយពុំមានការចូលរួមជាសាធារណៈ ឬមិនបានពេញលេញ ត្រូវផ្អាកជាបណ្តោះអាសន្ន និងត្រូវរៀបចំផែនការ និងអនុវត្តការចូលរួមជាសាធារណៈឲ្យបានពេញលេញក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីក្រមនេះចូលជាធរមាន។ |

| | | | |
|---|---|---|---|
| | ផែនការ និងអនុវត្តការចូលរួមជាសាធារណៈឲ្យបានពេញលេញក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីក្រមនេះចូលជាធរមាន។ | | |
| ៦ | **មាត្រា ៣៣** កាតព្វកិច្ចក្នុងការបើកបង្ហាញ និងដាក់ព័ត៌មានឲ្យសាធារណជនអាចស្វែងរកបាន<br>គ្រប់ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបើកបង្ហាញព័ត៌មាន ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះឲ្យ បានយ៉ាងហោចណាស់ ៣០ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីឲ្យ សាធារណជនអាចស្វែងរកបាន មុនពេលចេញ៖<br>១....<br>២.... | **មាត្រា ៣៥** កាតព្វកិច្ចក្នុងការបើកបង្ហាញ និងដាក់ព័ត៌មានឲ្យសាធារណជនអាចស្វែងរកបាន<br>គ្រប់ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបើកបង្ហាញព័ត៌មាន ដូចមានចែងក្នុងមាត្រា៣៧ នៃក្រមនេះឲ្យសាធារណជនអាចស្វែងរកបាន មុនពេលចេញ៖<br>១....<br>២.... | ស្នើពិចារណាសាជាថ្មីចំពោះសេចក្តីស្នើរបស់អង្គការសង្គមស៊ីវិល ដែលមានដូចខាងក្រោម៖<br>**មាត្រា ៣៣** កាតព្វកិច្ចក្នុងការបើកបង្ហាញ និងដាក់ព័ត៌មានឲ្យសាធារណជនអាចស្វែងរកបាន<br>គ្រប់ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបើកបង្ហាញព័ត៌មាន ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះឲ្យ បានយ៉ាងហោចណាស់ ៣០ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីឲ្យ សាធារណជនអាចស្វែងរកបាន មុនពេលចេញ៖<br>១....<br>២.... |
| ៧ | **មាត្រា៣៥** ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិមានដូចខាងក្រោម៖<br>ស្នើពិចារណាដាក់បញ្ចូលលក្ខខណ្ឌការងារសម្រាប់កិច្ចដំណើរការការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន<br>១៣. រាល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ~~កំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថា~~ | **មាត្រា៣៧** ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិមានដូចខាងក្រោម៖<br>១៣. រាល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ។ | ស្នើពិចារណាសាជាថ្មីចំពោះសេចក្តីស្នើរបស់អង្គការសង្គមស៊ីវិល ដែលមានដូចខាងក្រោម៖<br>មាត្រា៣៧ ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិមានដូចខាងក្រោម៖<br>លក្ខខណ្ឌការងារសម្រាប់កិច្ចដំណើរការការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន។ |

| | | | |
|---|---|---|---|
| | ~~ន~~ ដែលមិនស្ថិតក្នុងព័ត៌មានសំងាត់ដែលកំណត់ដោយក្រមនេះ។ | | |
| ៨ | **មាត្រា៣៨** ការផ្តល់ព័ត៌មានជាសាធារណៈ:<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានគ្រប់ទម្រង់រួមទាំងកំណត់ត្រា ឯកសារបោះពុម្ពផ្សាយ សម្លេង កាសែត ឯកសារអេឡិចត្រូនិក ជាសាធារណៈ នូវរាល់ប្រភេទព័ត៌មាន ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះ។ | **មាត្រា៤០** ការផ្តល់ព័ត៌មានជាសាធារណៈ:<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានជាសាធារណៈដូចមានចែងក្នុងមាត្រា៣៧ នៃក្រមនេះ។ | ស្នើពិចារណាសាជាថ្មីចំពោះសេចក្តីស្នើរបស់អង្គការសង្គមស៊ីវិល ដែលមានដូចខាងក្រោម៖<br>**មាត្រា៤០** ការផ្តល់ព័ត៌មានជាសាធារណៈ:<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានគ្រប់ទម្រង់រួមទាំងកំណត់ត្រា ឯកសារបោះពុម្ពផ្សាយ សម្លេង កាសែត ឯកសារអេឡិចត្រូនិក ជាសាធារណៈ: នូវរាល់ប្រភេទព័ត៌មាន ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះ។ |
| ៩ | **មាត្រា៤៣** ប្រភេទព័ត៌មាន នៃបញ្ជីព័ត៌មានបរិស្ថានជាតិ<br>បញ្ជីព័ត៌មានបរិស្ថានជាតិនេះ ត្រូវដាក់បញ្ចូលនូវព័ត៌មានទាំងអស់ដែលផ្តល់ឲ្យដោយក្រសួង ស្ថាប័នសមត្ថកិច្ច ស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ។<br>ប្រភេទព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ រួមមាន ស្ថិតិ របាយការណ៍រីកចម្រើន និងថវិកា និងព័ត៌មានភូមសាស្ត្រស្តីពីបរិស្ថាន ស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងធនធានធម្មជាតិ សកម្មភាពអភិវឌ្ឍ និងសិទ្ធិ | **មាត្រា៤៤** ប្រភេទព័ត៌មាន នៃបញ្ជីព័ត៌មានបរិស្ថានជាតិ<br>បញ្ជីព័ត៌មានបរិស្ថានជាតិនេះ ត្រូវដាក់បញ្ចូលនូវព័ត៌មានទាំងអស់ដែលផ្តល់ឲ្យដោយក្រសួង ស្ថាប័នសមត្ថកិច្ច ស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ។<br>ប្រភេទព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ រួមមាន ស្ថិតិ របាយការណ៍ និងព័ត៌មានភូមសាស្ត្រស្តីពីបរិស្ថាន ស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងធនធានធម្មជាតិ សកម្មភាពអភិវឌ្ឍ និងសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ជាអាទ៍។ | ស្នើពិចារណាសាជាថ្មីចំពោះសេចក្តីស្នើរបស់អង្គការសង្គមស៊ីវិល ដែលមានដូចខាងក្រោម៖<br>**មាត្រា៤៣** ប្រភេទព័ត៌មាន នៃបញ្ជីព័ត៌មានបរិស្ថានជាតិ<br>បញ្ជីព័ត៌មានបរិស្ថានជាតិនេះ ត្រូវដាក់បញ្ចូលនូវព័ត៌មានទាំងអស់ដែលផ្តល់ឲ្យដោយក្រសួង ស្ថាប័នសមត្ថកិច្ច ស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ។<br>ប្រភេទព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ រួមមាន ស្ថិតិ របាយការណ៍រីកចម្រើន របាយការណ៍ថវិកា និងព័ត៌មានភូមសាស្ត្រស្តីពីបរិស្ថាន ស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងធនធានធម្មជាតិ |

| | | | |
|---|---|---|---|
| | កាន់កាប់ដីធ្លីរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ជាអាទ៍។ | | សកម្មភាពអភិវឌ្ឍន៍ និងសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ជាអាទ៍។ |
| ១០ | **មាត្រា៥៣** ការរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ<br>ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយធ្វើការបោះពុម្ពរៀងរាល់ឆ្នាំ។ | **មាត្រា៥១** ការរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ<br>ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ។ | ស្នើពិចារណាសាជាថ្មីចំពោះសេចក្ដីស្នើរបស់អង្គការសង្គមស៊ីវិល ដែលមានដូចខាងក្រោមៈ<br>**មាត្រា៥១** ការរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ<br>ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំបញ្ជីសវនកម្មបរិស្ថានថ្នាក់ជាតិ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយធ្វើការបោះពុម្ពរៀងរាល់ឆ្នាំ។ |
| ១១ | **មាត្រា៥៩** ការកំណត់អំពីព័ត៌មានសម្ងាត់<br>……………………………………………………<br>ប្រភេទព័ត៌មានសម្ងាត់នីមួយៗគួរបញ្ជាក់ក្នុងជំពូកនេះឲ្យបានច្បាស់លាស់ ជៀសវាងការបកស្រាយផ្សេងៗគ្នា។ | **មាត្រា៥៧** ការកំណត់អំពីព័ត៌មានសម្ងាត់<br>ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសម្រេចយល់ព្រម ឬបដិសេធលើសំណើសុំចាត់ទុកព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ដោយត្រូវបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ។ ការធ្វើសេចក្ដីសម្រេចនេះ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន។<br>នីតិវិធី និងលក្ខណៈវិនិច្ឆ័យសម្រាប់ការកំណត់ព័ត៌មានសម្ងាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។ | ស្នើពិចារណាសាជាថ្មីចំពោះសេចក្ដីស្នើរបស់អង្គការសង្គមស៊ីវិល ដែលមានដូចខាងក្រោមៈ<br>ស្នើសុំរៀបរាប់ពីប្រភេទព័ត៌មានបរិស្ថានជាក់លាក់ទាំងឡាយណា ដែលត្រូវបានចាត់ទុកថា ជាព័ត៌មានសម្ងាត់ ជៀសវាងការបកស្រាយផ្សេងគ្នា។(រាយនាមបញ្ជីឈ្មោះព័ត៌មានសម្ងាត់) |
| ១២ | ផ្នែកទី៣ មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ<br>ស្នើប្ដូរទៅជា មជ្ឈមណ្ឌលព័ត៌មានភូមិសាស្ត្របរិស្ថានជាតិ | ជំពូកទី៥ មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ និងរបាយការណ៍បរិស្ថានជាតិ | ស្នើប្ដូរទៅជា មជ្ឈមណ្ឌលព័ត៌មានភូមិសាស្ត្រ បរិស្ថានជាតិ |

| | | | |
|---|---|---|---|
| ១៣ | មាត្រា៤៧ ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ<br>១...<br>២. មានមុខងារក្នុងការសម្រិតសម្រាំងស្ថិតិ ទិន្នន័យមូលដ្ឋានបរិស្ថាន ទិន្នន័យភូមិសាស្ត្រដូចជាការប្រើប្រាស់ដី តំបន់ការធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងព័ត៌មានភូមិសាស្ត្រផ្សេងៗទៀត ~~ផែនទី~~ ដែលផ្តល់ឲ្យដោយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត រៀបចំ និងរក្សាបញ្ជីទិន្នន័យ ព័ត៌មាន សម្រាប់ទំនាក់ទំនង និងបែបបទសម្រាប់ការស្នើសុំទិន្នន័យ។<br>៣.....<br>៤. ចងក្រង និងបញ្ចូលទិន្នន័យមូលដ្ឋាន និងភូមិសាស្ត្រផ្សេងៗដូចជាការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងរបាយការណ៍ពាក់ព័ន្ធនឹងការកំណត់ផែនទីបរិស្ថាន និងធនធានធម្មជាតិ ដែលរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធទៅក្នុងបញ្ជីព័ត៌មានបរិស្ថានជាតិ។<br>៥. រៀបចំស្តង់ដារនានាសម្រាប់ការប្រមូល ការចូលរួមប្រមូលទិន្នន័យ ការគ្រប់គ្រង ការវិភាគ និងការបែងចែក ព័ត៌មាន | មាត្រា៦៣ ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ<br>១.....<br>២. មានមុខងារក្នុងការសម្រិតសម្រាំងស្ថិតិ ទិន្នន័យភូមិសាស្ត្រដូចជាការប្រើប្រាស់ដី និងព័ត៌មានផែនទី ដែលផ្តល់ឲ្យដោយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត រៀបចំ និងរក្សាបញ្ជីទិន្នន័យព័ត៌មាន សម្រាប់ទំនាក់ទំនង និងបែបបទសម្រាប់ការស្នើសុំទិន្នន័យ។<br>៣.....<br>៤. ចងក្រង និងបញ្ចូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី និងរបាយការណ៍ពាក់ព័ន្ធនឹងការកំណត់ផែនទីបរិស្ថាន និងធនធានធម្មជាតិ ដែលរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធទៅក្នុងបញ្ជីព័ត៌មានបរិស្ថានជាតិ។<br>៥. រៀបចំស្តង់ដារនានាសម្រាប់ការប្រមូល ការគ្រប់គ្រង ការវិភាគ និងការបែងចែក ព័ត៌មានភូមិសាស្ត្រនៃការប្រើប្រាស់ដី។<br>៦.......<br>៧. កំណត់ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី ដោយមានការធានាគុណភាព និង | ស្នើពិចារណាសាជាថ្មីចំពោះសេចក្តីស្នើរបស់អង្គការសង្គមស៊ីវិល ដែលមានដូចខាងក្រោម៖<br>**មាត្រា៦៣ ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ**<br>១.....<br>២. មានមុខងារក្នុងការសម្រិតសម្រាំងស្ថិតិ ទិន្នន័យមូលដ្ឋានបរិស្ថាន ទិន្នន័យភូមិសាស្ត្រដូចជាការប្រើប្រាស់ដី តំបន់ការធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងព័ត៌មាន ភូមិសាស្ត្រផ្សេងៗទៀត ~~ផែនទី~~ ដែលផ្តល់ឲ្យដោយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត រៀបចំ និងរក្សាបញ្ជីទិន្នន័យ ព័ត៌មាន សម្រាប់ទំនាក់ទំនង និងបែបបទសម្រាប់ការស្នើសុំទិន្នន័យ។<br>៣.....<br>៤. ចងក្រង និងបញ្ចូលទិន្នន័យមូលដ្ឋាន និងភូមិសាស្ត្រផ្សេងៗដូចជា ការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងរបាយការណ៍ពាក់ព័ន្ធនឹងការកំណត់ផែនទីបរិស្ថាន និងធនធានធម្មជាតិដែលរៀបចំដោយក្រសួង ស្ថាប័ន ពាក់ព័ន្ធទៅក្នុងបញ្ជីព័ត៌មានបរិស្ថានជាតិ។<br>៥. រៀបចំស្តង់ដារនានាសម្រាប់ការប្រមូល ការចូលរួមប្រមូលទិន្នន័យ ការគ្រប់គ្រង ការវិភាគ |

| | | | |
|---|---|---|---|
| | ភូមិសាស្ត្រនៃការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ។<br>៦……..<br>៧. កំណត់ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ ដោយមានការធានាគុណភាព និងដោយភ្ជាប់មកជាមួយនូវបណ្តុំទិន្នន័យដែលមានស្រាប់។<br>៨. ប្រមូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងទិន្នន័យពាក់ព័ន្ធនឹងវិស័យជាក់លាក់ណាមួយ។ ការប្រមូលនេះ មិនត្រូវជាន់គ្នានឹងព័ត៌មាន ឬទិន្នន័យ ក្នុងចំណោមក្រសួង ស្ថាប័ននានាឡើយ។<br>៩. ចងក្រង កត់ត្រា ទុកដាក់ និងចែករំលែកនូវព័ត៌មានទិន្នន័យមូលដ្ឋាន ព័ត៌មានភូមិសាស្ត្រអំពីគម្រោងអភិរក្សនានា គម្រោងអភិវឌ្ឍន៍នានាក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានកិច្ចសន្យាការពារបរិស្ថាន ការវាយតម្លៃបឋមបរិស្ថាន និងការវាយតម្លៃបរិស្ថានពេញលេញ។ | ដោយភ្ជាប់មកជាមួយនូវបណ្តុំទិន្នន័យដែលមានស្រាប់។<br>៨. ប្រមូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី និងទិន្នន័យពាក់ព័ន្ធនឹងវិស័យជាក់លាក់ណាមួយ។ ការប្រមូលនេះ មិនត្រូវជាន់គ្នានឹងព័ត៌មាន ឬទិន្នន័យ ក្នុងចំណោមក្រសួង ស្ថាប័ននានាឡើយ។ | និងការបែងចែក ព័ត៌មានភូមិសាស្ត្រនៃការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ។<br>៦……..<br>៧. កំណត់ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ ដោយមានការធានាគុណភាព និងដោយភ្ជាប់មកជាមួយនូវបណ្តុំទិន្នន័យដែលមានស្រាប់។<br>៨. ប្រមូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងទិន្នន័យពាក់ព័ន្ធនឹងវិស័យជាក់លាក់ណាមួយ។ ការប្រមូលនេះ មិនត្រូវជាន់គ្នានឹងព័ត៌មាន ឬទិន្នន័យ ក្នុងចំណោមក្រសួង ស្ថាប័ននានាឡើយ។<br>៩. ចងក្រង កត់ត្រា ទុកដាក់ និងចែករំលែកនូវព័ត៌មានទិន្នន័យមូលដ្ឋាន ព័ត៌មានភូមិសាស្ត្រអំពីគម្រោងអភិរក្សនានា គម្រោងអភិវឌ្ឍន៍នានាក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានកិច្ចសន្យាការពារបរិស្ថាន ការវាយតម្លៃបឋមបរិស្ថាន និងការវាយតម្លៃបរិស្ថានពេញលេញ។ |
| | មតិយោបល់បន្ថែម៖<br>មាត្រា៩៩ លក្ខខណ្ឌក្នុងការបដិសេធសំណើដោយក្រសួងបរិស្ថាន ស្ថាប័នពាក់ព័ន្ធ | | |

| | |
|---|---|
| | ក្រសួង ស្ថាប័នពាក់ព័ន្ធ មានសិទ្ធិបដិសេធការស្នើសុំព័ត៌មាន ក្នុងករណី ដូចខាងក្រោម៖<br>១…..<br>២. ~~សំណើសុំមិនមានបញ្ជាក់ហេតុផលត្រឹមត្រូវ។~~ (គួរដកចេញដោយសារវារឹតត្បិតលទ្ធភាពទទួលបានព័ត៌មានរបស់សាធារណជន។)<br>មាត្រា៦០ លក្ខខណ្ឌក្នុងការបដិសេធសំណើដោយម្ចាស់គម្រោង<br>ម្ចាស់គម្រោងអាចបដិសេធការស្នើសុំបង្ហាញព័ត៌មាន ដោយរូបវន្តបុគ្គល ឬនីតិបុគ្គល ក្នុងលក្ខខណ្ឌដូចខាងក្រោម៖<br>១…..<br>២. ~~សំណើសុំមិនមានបញ្ជាក់ហេតុផលត្រឹមត្រូវ។~~ គួរដកចេញដោយសារវារឹតត្បិតលទ្ធភាពទទួលបានព័ត៌មានរបស់សាធារណជន។ |

**មតិយោបល់របស់អង្គការសង្គមស៊ីវិល**
**លើសេចក្តីព្រាងទី១១ នៃក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា**
**ប្រធានបទ ៖ ប្រព័ន្ធតំបន់ការពារធម្មជាតិ និង ការគ្រប់គ្រង ការការពារ និងការអភិរក្សសត្វព្រៃ**

| លរ | មតិយោបល់/សំណូមពររបស់សង្គមស៊ីវិល លើសេចក្តីព្រាងទី១០ | គន្លឹ/មាតិកា/ជំពូកនៃសេចក្តីព្រាងទី១១ | មតិយោបល់/សំណូមពរ/កំណែប្រែថ្មី លើសេចក្តីព្រាងទី១១ |
|---|---|---|---|
| ១ | ស្នើរបន្ថែមមាត្រាថ្មី៖ការកំណត់តំបន់សម្រាប់សកម្មភាពពាណិជ្ជកម្ម] និងចែងលំអិតអំពីគោលការណ៍ និងលក្ខណៈវិនិច្ឆ័យនៃការកំណត់ | មាត្រា ៣១៤៖ ការកំណត់តំបន់ សម្រាប់សកម្មភាពពាណិជ្ជកម្ម | **គួរបន្ថែមសេចក្តីលំអិតអំពីគោលការណ៍ និងលក្ខណៈវិនិច្ឆ័យនៃការកំណត់តំបន់សម្រាប់សកម្មភាពពាណិជ្ជកម្មដូចបានរៀបរាប់ក្នុងកថាខណ្ឌខាងក្រោម៖**<br>[នៅពេលដែលមានការបំពេលលក្ខណៈវិនិច្ឆ័យដូចមានចែងខាងលើ ស្ថាប័នទទួលខុសត្រូវគួរមានការបង្កើតអនុតំបន់ថ្មីដើម្បីបញ្ចូលតំបន់សម្រាប់សកម្មភាពពាណិជ្ជកម្ម ដូចជា តំបន់ទេសចរណ៍ តំបន់អភិវឌ្ឍកសិកម្មរបស់សហគម ឬតំបន់ផ្សេងទៀតតាមការចាំបាច់។<br><br>ក្រោយមានបង្កើតអនុតំបន់នេះ ស្ថាប័នទទួលខុសត្រូវគួរចូលរួមរៀបចំសកម្មភាពពាណិជ្ជកម្មទាំងអស់នោះ។ ចំណូលដែលមានទទួលពីសកម្មភាពពាណិជ្ជកម្មអស់នោះគួរតែដាក់ចូលទៅក្នុងគណនីសម្រាប់ការគ្រប់គ្រងដូចដែលបានចែងក្នុងគន្លឹទី៨ ជំពូកទី២នៃក្រមនេះ ហើយនឹងត្រូវបានចាត់ចែងប្រើប្រាស់សម្រាប់បម្រើផលប្រយោជន៍សហគមន៍មូលដ្ឋានស្ថិតក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ។ |

| | | | |
|---|---|---|---|
| | | | ដំណើរការនេះការរៀបចំអនុតំបន់សកម្មភាពពាណិជ្ជកម្ម និងដំណើរលំអិតនៃការរៀបចំសកម្មភាពទាំងអស់នេះគួរមានការបើកទូលាយសម្រាប់សាធារណជនចូលរួមផ្តល់យោបល់ស្របតាមគោលការណ៍ការចូលរួមជាសាធារណៈដែលបានចែងក្នុងគន្ថីទី១ ជំពូក២ និង៣នៃក្រមនេះ។] |
| ២ | ស្នើរបន្ថែមមាត្រាថ្មី៖គ្រប់គ្រងរបៀងជីវៈចម្រុះ | មាត្រា ៣២៤: ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិប្រព័ន្ធតំបន់ការពារធម្មជាតិត្រូវទទួលបានសិទ្ធគ្រប់គ្រងរួម ស្របតាមបទបញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ ។ តំបន់គ្រប់គ្រងរួមគ្នាដែលត្រូវបានបង្កើតឡើងនៅក្នុងផ្នែកណាមួយនៃប្រព័ន្ធការពារធម្មជាតិត្រូវគ្រងគ្រងតាមបទប្បញ្ញត្តិដូចមានចែងក្នុងក្រមនេះ | **ស្នើបន្ថែមលក្ខ័ខណ្ឌដូចខាងក្រោម៖**<br>[ប្រព័ន្ធតំបន់ការពារធម្មជាតិ និងតំបន់ការពារធម្មជាតិដែលបានដាក់បញ្ចូលក្រោមការគ្រប់គ្រងរួមគួរមានការលើកលែងចំពោះតំបន់ដែលមានសារៈសំខាន់សម្រាប់ជីវៈចម្រុះសកល។ តំបន់ដែលគួរមានការមានការដកចេញពីការគ្រប់គ្រងរួមគឺជាតំបន់ដែលមានតំបន់ជីវៈចម្រុះខុសគ្នាពីតំបន់ផ្សេងទៀងដែលបានបញ្ចូលទៅក្នុងការគ្រប់គ្រងរួម។ តំបន់ដែលដកចេញពីតំបន់គ្រប់គ្រងរួមគួរតំបន់ឱ្យមានត្រឹម១០ភាគរយនៃតំបន់គ្រប់គ្រងរួមរបស់ប្រព័ន្ធតំបន់ការពារ។] |
| ៣ | | មាត្រា៣២៦៖ ការបន្តសុពលភាព សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ តំបន់ទទួលស្គាល់តាមប្រពៃណី និងសហគមន៍មូលដ្ឋានដទៃទៀតដែលមានស្រាប់ នៅពេលក្រមនេះចូលជាធរមាន ត្រូវបន្តសុពលភាព សិទ្ធ ការទទួលខុសត្រូវ និងកាតព្វកិច្ចទាំងអស់ ស្របច្បាប់ លើកលែងតែរហូតដល់ពេលដែលសហគមន៍នីមួយៗអាចត្រូវបាន | **ស្នើសុំឱ្យដូរ៖**<br>[លើកលែងតែរហូតដល់ពេលដែលសហគមន៍នីមួយបានសម្រេចចិត្តដោយស្មគ្រ័ចិត្តដើម្បីបង្កើត ឫប្រែក្លាយទៅជាតំបន់គ្រប់គ្រងរួម] |

| | | | |
|---|---|---|---|
| | | បញ្ចូលទៅក្នុង ឬប្រែក្លាយទៅជាតំបន់គ្រប់គ្រងរួមគ្នា ដូចមានចែងនៅក្នុងក្រមនេះ។ | |
| ៤ | ស្នើរបន្ថែមមាត្រាថ្មី៖ការហាមឃាត់ចំពោះសកម្មភាពនេសាទ | **មាត្រា ៣៣៣៖** ការហាមឃាត់ចំពោះសកម្មភាពនេសាទ<br>ការនេសាទនៅក្នុងតំបន់ស្នូលនៃតំបន់ការពារធម្មជាតិត្រូវបានហាមឃាត់………………ដើម្បីធានាថាមិនមានផលប៉ះពាល់អវិជ្ជមានណាមួយនៅជុំវិញតំបន់នោះ។ | អាចទទួលយកបាន |
| ៧ | ស្នើរបន្ថែមមាត្រាថ្មី៖ការប្រមូលជ័រឈើ | **មាត្រា ៣៣៦** ការប្រមូលផលជ័រឈើ<br>ការប្រមូលផលជ័រឈើ នៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិ...................................កត់ត្រាទុកជាលាយលក្ខណ៍អក្សរដោយមានមូលហេតុត្រឹមត្រូវ។ | **ស្នើ៖** ការប្រើប្រាស់ជាលក្ខណៈគ្រួសារគួរត្រូវបានអនុញ្ញាត និងមានចែងក្នុងច្បាប់ជាក់លាក់។ |
| ៨ | | **មាត្រា ៣៨៣** គោលបំណង<br>សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច......................ស្របតាមបទបញ្ញត្តិ ដូចមានចែងក្នុងក្រមនេះ។ | អាចទទួលយកបាន |
| ៩ | មាត្រា...ការប្រើប្រាស់អុស និងធ្យូងដោយចីរភាព<br>ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ត្រូវលើកកម្ពស់ផលិតកម្ម និងការប្រើប្រាស់អុស ធ្យូងដោយចីរភាព ។<br>ក្រសួង ស្ថាប័នមានសមត្ថកិច្ចទទួលបន្ទុកគ្រប់គ្រងព្រៃឈើ ដោយសហការជាមួយសហ | **មាត្រា ៣៨៤** សិទ្ធប្រើប្រាស់ជាលក្ខណៈប្រពៃណី | អាចទទួលយកបាន |

| | | | |
|---|---|---|---|
| | គមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងដៃគូបច្ចេកទេស ត្រូវរៀបចំវិញ្ញាបនបត្រគ្រប់គ្រងសហគ្រាសផលិតអុស ធ្យូង និងលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំយន្តការសម្រាប់ការចេញលិខិតបញ្ជាក់ និងគ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធ ដល់ផលិតករអុសធ្យូងដោយចីរភាពដែលទទួលបានលិខិតអនុញ្ញាត ។ | | |
| ១០ | **ARTICLE 365 PERMIT REQUIREMENT AND PROHIBITION**<br>The introduction of any Alien Wild Species into the natural environment outside of the Natural Protected Area System shall require a permit from the ministry or institution responsible for environment.<br><br>The introduction of any Alien Wild Species inside any area of the Natural Protected Area System shall be prohibited | **មាត្រា៤៨០** ការធ្វើពាណិជ្ជកម្មក្នុងស្រុក ត្រូវហាមឃាត់រាល់ការធ្វើពាណិជ្ជកម្មក្នុងស្រុកទៅលើប្រភេទសត្វព្រៃ.......................ដូចមានចែងក្នុងបទ | **<u>ស្នើ៖</u>** ត្រូវដាក់ទោសទណ្ឌទាំងអ្នកបរិភោគសាច់សត្វផងដែរ។ ដោយយោងតាម ប្រភេទសត្វដែលមានចែងក្នុងចំណាត់ថ្នាក់ ឬអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើពីប្រភេទសត្វ និងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់ (CITES) ក្នុងប្រទេសកម្ពុជា។ |
| ១១ | **CHAPTER 5: HUNTING, COLLECTING, AND TRADE**<br><br>**ARTICLE 366 NON-ISSUANCE OF PERMITS**<br>The ministry or institution responsible for environment shall not issue permits under this Title without sufficient scientific information to determine the impact of an activity on the conservation status of the wild species, except for permits granted strictly for scientific purposes. | **មាត្រា ៤៧២** លិខិតអនុញ្ញត្តិបរបាញ់សត្វព្រៃ ការបរបាញ់សត្វព្រៃដូចបានកំណត់នៅក្នុងបញ្ជីចំណាត់ថ្នាក់ទី៣ ...........................និងតំបន់គ្រប់គ្រងរួមគ្នា នៃប្រព័ន្ធតំបន់ការពារធនធានធម្មជាតិ។ | អាចទទួលយកបាន |
| ១២ | មាត្រា...ការមិនចេញលិខិតអនុញ្ញាត ស្ថាប័នទទួលបន្ទុកបរិស្ថាន មិនត្រូវចេញ ក្រសួងលិខិតអនុញ្ញាតក្រោមមាតិកានេះក្នុងករណីដែល | មាត្រា៣៨០  សកម្មភាពពាក់ព័ន្ធ | មានលក្ខណៈទូទៅច្រើនពេក អាចប៉ះពាល់ផលវិបាកពេលអនាគត។ |

| | | | |
|---|---|---|---|
| | មិនមានព័ត៌មានផ្នែកវិទ្យាសាស្ត្របញ្ជាក់គ្រប់គ្រាន់ដើម្បីកំណត់ពីផលប៉ះពាល់នៃសកម្មភាពទៅលើស្ថានភាពអភិរក្សនៃប្រភេទសត្វ រុក្ខជាតិព្រៃនោះ លើកលែងតែការអនុញ្ញាតនោះ ធ្វើឡើងសម្រាប់តែគោលបំណងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រប៉ុណ្ណោះ ។ | រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលស្នើឲ្យធ្វើសកម្មភាពណាមួយខាងក្រោមក្នុងតំបន់ព្រៃឈើដែលគ្រប់គ្រង............ដែលមានសមត្ថកិច្ច៖<br>១. ផលិតផលដែលបានពី.......<br>២.......<br>.........<br>១២.......... | **ស្នើ៖** គួរអនុញ្ញាតអាចធ្វើឡើងសម្រាប់តែគោលបំណងស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រប៉ុណ្ណោះ។ |
| ១៣ | មាត្រា... វិសាលភាពនៃផែនការគ្រប់គ្រង<br>ផែនការគ្រប់គ្រងត្រូវបង្កើតឡើងសម្រាប់រាល់សកម្មភាពពាណិជ្ជកម្មទាំងអស់ដែលធ្វើឡើងចំពោះព្រៃឈើដែលគ្រប់គ្រងដោយនិរន្តរភាពនីមួយៗ និងត្រូវសមាមាត្រទៅនឹងទំហំ អាំងតង់ស៊ីតេ និងហានិភ័យសកម្មភាពពាណិជ្ជកម្មទាំងនោះ ។ ផែនការគ្រប់គ្រងត្រូវអនុវត្ត និងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដោយផ្អែកលើព័ត៌មានអង្កេតតាមដានដើម្បីលើកកម្ពស់ការគ្រប់គ្រងដែលអាចសម្រប<br>បាន ។ | **មាត្រា ៣៨៥** វិសាលភាពនៃផែនការគ្រប់គ្រង<br>ផែនការគ្រប់គ្រង..................................ឈើដោយនិរន្តរភាព។ | អាចទទួលយកបាន |
| ១៤ | មាត្រា... ការចេញលិខិតអនុញ្ញាតបរបាញ់<br>រាល់ទម្រង់បែបបទនៃការស្នើសុំ វិញ្ញាបនប័ត្រឯកភាព និងលិខិតអនុញ្ញាតបរបាញ់ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ | **មាត្រា ៤៧៥** ការចេញលិខិតអនុញ្ញាត<br>ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន.<br>......ទទួលបន្ទុកបរិស្ថាន និងធនធានធម្មជាតិ។ | អាចទទួលយកបាន |

| | | | |
|---|---|---|---|
| | ការអនុញ្ញាត ការដកហូតលិខិតអនុញ្ញាត ឬបដិសេធចំពោះលិខិតអនុញ្ញាត ឬលក្ខខណ្ឌ ដែលកំណត់ ត្រូវធ្វើឡើងស្របតាមការយល់ឃើញថាសមរម្យរបស់នាយកមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត គណៈកម្មការគ្រប់គ្រងរួមគ្នា ឬនាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្អែកលើលក្ខខណ្ឌតម្រូវដូចតទៅ៖<br>ក-រាល់លិខិតអនុញ្ញាត ត្រូវចេញដោយមានតម្លាភាព ។<br>ខ-មួយគ្រួសារអាចទទួលបានលិខិតអនុញ្ញាតតែមួយប៉ុណ្ណោះ ។<br>គ-មិនត្រូវមានការចេញលិខិតអនុញ្ញាតសម្រាប់ជនទាំងឡាយណាដែលមានពាក់ព័ន្ធនឹងការបរបាញ់ខុសច្បាប់ដែលមានរយៈពេល ៥ (ឆ្នាំ) ជាអតិបរិមា ឬមានការដកហូតលិខិតអនុញ្ញាត ៣ (បី) ដង ដូចបានកំណត់ក្នុងមាត្រា ៤៣០ នៃក្រមនេះ ។<br>ឃ-មិនត្រូវមានការចេញលិខិតអនុញ្ញាតសម្រាប់ជនទាំងឡាយណាដែលនាយកមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្ត គណៈកម្មការគ្រប់គ្រងរួមគ្នា ឬនាយករបៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានហេតុផលបង្ហាញ | | |

| | | | |
|---|---|---|---|
| | ឬជឿថា ធ្លាប់មានពាក់ព័ន្ធទៅនឹងការបបាញ់ក្នុងគោលដៅអាជីវកម្ម និងអាជីវកម្មសត្វព្រៃមិនស្របច្បាប់ឡើយ ។<br>ង-ហាមមិនឲ្យមានការផ្ទេរលិខិតអនុញ្ញាតបបាញ់ពីបុគ្គលម្នាក់ទៅបុគ្គលឯទៀតនោះឡើយ ។ | | |
| ១៥ | ស្នើបន្ថែមមាត្រាថ្មីអំពីការហាមឃាត់<br>ហាមឃាត់មិនឲ្យមាន ការបង្កើតកសិដ្ឋានចិញ្ចឹមសត្វព្រៃ ឬទីតាំងបង្កាត់ពូជសត្វព្រៃដទៃទៀត ដោយគ្មានការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថានឡើយ ។<br>ហាមមិនឲ្យមាន ការចិញ្ចឹម រក្សាទុក បង្កាត់ពូជ ស្តុកទុក ឬថែទាំ សត្វព្រៃណាមួយ ក្នុងកសិដ្ឋានសត្វព្រៃ ឬទីតាំងបង្ខាំងសត្វព្រៃដទៃក្នុងចម្ងាយ ២០ (ម្ភៃ) គីឡូម៉ែត្រ ពីរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិ ដែលកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នោះឡើយ ។<br>ហាមមិនឲ្យដាក់បញ្ចូលសត្វព្រៃដែលចាប់បានពីព្រៃចូលទៅក្នុងកសិដ្ឋានចិញ្ចឹមសត្វព្រៃនោះឡើយ ។ កសិដ្ឋានចិញ្ចឹមសត្វព្រៃ ត្រូវទទួល និងទិញសត្វព្រៃពីកសិដ្ឋានដទៃទៀតដែលមានវិញ្ញាបនបត្រឯកភាពដែលមានសុពលភាពតែប៉ុណ្ណោះ ។ | **មាត្រា ៥១១** សកម្មភាពហាមឃាត់ដែលប៉ះពាល់ដល់ទីជម្រក............ការគំរាមកំហែង<br>សកម្មភាពបំផ្លិចបំផ្លាញ.............ជំពូកទី៤ នៃមាត្រានេះ។ | អាចទទួលយកបាន |
| ១៦ | | **មាត្រា ៥១២** សកម្មភាពហាមឃាត់ចំពោះរុក្ខជាតិ..........ជំពូកទី៤ នៃមាត្រានេះ។ | អាចទទួលយកបាន |

| | | | |
|---|---|---|---|
| ១៧ | បន្ថែមមាត្រាថ្មី៖ ការលក់ដូរសត្វព្រៃចិញ្ចឹម និងផលិតផលសត្វព្រៃ | **មាត្រា ៥១៦** ការលក់សត្វព្រៃចិញ្ចឹម និងផលិតផលសត្វព្រៃ | អាចទទួលយកបាន |
| ១៨ | <u>មតិយោបល់បន្ថែម (បើមាន) ៖</u><br>មាត្រា ៣១១ ការកំណត់តំបន់គ្រប់គ្រង<br>• ចំណុចទី៤ តំបន់សហគមន៍ ៖ មិនគួរចាត់បញ្ចូលដីលំនៅដ្ឋាន វាលស្រែ វាលចម្ការ ឬចម្ការវិលជុំ ដីអារក្ស ដីកប់សព និងដីបំរុងទុកជាតំបន់សហគមន៍ឡើយ អនុលោមតាម ច្បាប់តំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ (ការផ្តល់ប័ណ្ណកម្មសិទ្ធដីធ្លី និងផ្តល់ការអនុញ្ញាតិឱ្យប្រើប្រាស់ដីគួរមានការយល់ព្រមជាមុនពីក្រសួងបរិស្ថានស្របតាមច្បាប់ដីធ្លី។)<br>មាត្រា ៣៨១ និង មាត្រា៣៨២ គួរពិគ្រោះយោបល់ ជាសាធារណៈមិនគួរពិគ្រោះយោបល់តែជាមួយភាគីពាក់ព័ន្ធ មិនគ្រប់គ្រាន់ទេ។<br>មាត្រា៣៨៩ សូមចែងអត្រាបែងចែកឱ្យច្បាស់លាស់ ដោយកំណត់៥០% នៃតម្លៃសរុបសម្រាប់សហគមន៍។<br>មាត្រា៤១១ ដល់ មាត្រា៤១៣ យោបល់សូមពិចារណា ពីការទាញយកអនុផលព្រៃឈើ មកបំពីកម្រិតជីវភាពប្រចាំថ្ងៃ ការហាមដាច់ខាតនឹវាងប៉ះពាល់ កសិករតូចតាច( ឧ.ដើមអង្គាសីល ដើមអរគីដេ ដើមប្រង់…) គួរកំណត់ ទំហំ បរិមាណជាក់លាក់ ក្នុងការហាមឃាត់។<br><br>**<u>ស្នើបន្ថែមមាត្រាថ្មី: សកម្មភាពហាមឃាត់នៅក្នុងតំបន់នៃតំបន់ការពារធម្មជាតិ</u>**<br>• តំបន់ស្នូល– ហាមឃាត់ចំពោះសកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទមានជាអាទិ៍ការរុករករ៉ែ ការបូមច្រោះ និងការទាញយកខ្សាច់ ការផលិកអគ្គិសនី ប្រព័ន្ធបញ្ជូន ឫចែកចាយអគ្គិសនី ការប្រើម៉ាស៊ីនដឹកជញ្ជូន ដំណាំកសិកម្ម វារីវប្បកម្មគ្រប់ប្រភេទ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងធនធានទឹក រួមប្រព័ន្ធធារាសាស្រ្ត និងទំនប់ទឹកគ្រប់ប្រភេទ ការប្រើប្រាស់ដើម្បីចិញ្ចឹមជីវិត និងជាលក្ខណៈប្រពៃណី ឫការចិញ្ចឹមសត្វ ការកាប់ឈើ ការបរបាញ់ និងការប្រើប្រាស់សម្ភារៈ ឫអន្ទាក់គ្រប់ប្រភេទដែលប៉ះពាល់ ឫសំលាប់សត្វ។<br>• តំបន់អភិរក្ស-ហាមឃាត់ចំពោះការរុករករ៉ែ ការបូមច្រោះ និងការទាញយកខ្សាច់ ការផលិតអគ្គិសនី ប្រព័ន្ធបញ្ជូន ឫចែកចាយអគ្គិសនី ការប្រើម៉ាស៊ីនដឹកជញ្ជូនដំណាំកសិកម្មវារីវប្បកម្មគ្រប់ប្រភេទ ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងធនធានទឹករួមមានប្រព័ន្ធធារាសាស្រ្ត និងទំនប់ទឹកគ្រប់ប្រភេទ ការប្រើប្រាស់ដើម្បីចិញ្ចឹមជិវិត និងជាលក្ខណៈប្រពៃណី ឫការចិញ្ចឹមសត្វ និងគ្រប់សកម្មភាពពាណិជ្ជកម្មទាំងអស់ លើកលែងតែទេសចរណ៍ធម្មជាតិដែលមានផលប៉ះពាល់តិចតួចប៉ុណ្ណោះ។ | | |

**មតិយោបល់របស់អង្គការសង្គមស៊ីវិល**

**លើសេចក្តីព្រាងទី១១ នៃក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា**

**ប្រធានបទ៖ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ**

| លរ | មតិយោបល់/សំណូមពររបស់សង្គមស៊ីវិល លើសេចក្តីព្រាងទី១០ | គន្លឹ/មាតិកា/ជំពូក | មតិយោបល់/សំណូមពរ/កំណែប្រែថ្មី លើសេចក្តីព្រាងទី១១ |
|---|---|---|---|
| ១ | **មាត្រា៦៤** ក្របខ័ណ្ឌនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ<br><br>គោលនយោបាយ ផែនការ និងកម្មវិធីនានា ដែលបានរៀបចំឡើងដោយក្រសួង ស្ថាបន័មានសមត្ថកិច្ច ត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ស្របតាមបទបញ្ញត្តិនៃក្រម មុនបញ្ជូលទៅរាជរដ្ឋាភិបាលសម្រេច។ | **មាត្រា៦៩** ក្របខ័ណ្ឌនៃការវាយតម្លៃបរិស្ថាន<br><br>រាល់ការរៀបចំគោលនយោបាយ ផែនការ និងកម្មវិធីរបស់រដ្ឋាភិបាល ចាំបាច់ត្រូវដាក់បញ្ចូលការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។ | **ស្នើ៖** ឱ្យរក្សាតាមពង្រាងទី១០ |
| ២ | **មាត្រា៦៥** វិសាលភាព | **មាត្រា៧១** វិសាលភាពនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ...។ (ក្នុងជំពូកទី២ នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ) | **ស្នើ៖** គួរតែប្តូរមាត្រានេះទៅក្រោមជំពូក១ នៃបទបញ្ញត្តិទូទៅ បន្ទាប់ពីមាត្រា៦៩។ |
| ៣ | **មាត្រា៦៩** នីតិវិធី....... | **មាត្រា៧៣** នីតិវិធី...................<br>១. .......<br>៤...........វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ។ | **ស្នើ៖** ដាក់បន្ថែមនូវ**នីតិវិធីលម្អិត** (គួរចែកបន្ថែមនូវនីតិវីធីលម្អិតនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ នៅក្នុងនីតិវិធីដាច់ដោយឡែកដើម្បីណែនាំឱ្យបានច្បាស់)។ |
| ៤ | **មាត្រា៧០** សមត្ថកិច្ច<br>ក្រសួង ស្ថាប័ន...................ជាយុទ្ធសាស្ត្រ។ | **មាត្រា៧៥** សមត្ថកិច្ច<br>ក្រសួង ស្ថាប័ន...................ជាយុទ្ធសាស្ត្រ។ | ទទួលយកបាន |

| | | | |
|---|---|---|---|
| ៥ | **ជំពូកទី៣** (មាត្រា៧៤, ៧៥ និង ៧៦) | **មាត្រា៧៦** ការចូលរួមពីសំណាក់ស្ត្រី និងជនងាយរងគ្រោះ | អាចទទួលយកបាន<br>**<u>ស្នើ៖</u>** ការកំណត់មាត្រាយោងទៅ ការចូលរួមជាសាធារណៈក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ (**<u>ខុស</u>** មិនមែនមាត្រា៧៣ ទេ ដូចនេះ**<u>សូមប្តូរទៅមាត្រា៧៤</u>**នៃក្រមនេះ)។ |
| ៦ | **មាត្រា៧៧** ការអនុវត្តនូវរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ក្នុងជំពូក៤ | **មាត្រា៧៨** ការអនុវត្តនូវរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ<br>ក្រសួង ស្ថាប័ន.............................. ដោយចីរភាព។<br>ប្រភេទគម្រោង..........................ក្នុងការអនុវត្ត។<br>ប្រភេទគម្រោងដែលស្ថិតក្នុងក្រៅវិសាលភាពនៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវបន្តរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាតិកាទី២ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រមនេះ។ | **មាត្រា៧៨** ជាទូទៅគ្រប់គម្រោងស្នើសុំត្រូវមានការវាយតម្លៃបរិស្ថាន ហើយការធ្វើការវាយតម្លៃបរិស្ថានជាយុទ្រសាស្ត្រដើម្បីពិនិត្យមើលលើផលប៉ះពាល់ជាបណ្តុំនៃបណ្តាគម្រោងអភិវឌ្ឍន៍។ ដូចដូច្នេះមានមាត្រា៧៨ គួរចែងដូចខាងក្រោម៖<br>ក្រសួង ស្ថាប័ន........................................... ដោយចីរភាព។<br>ប្រភេទគម្រោង............................................ក្នុងការអនុវត្ត។<br>ប្រភេទគម្រោងដែលស្ថិត**<u>នៅក្នុងឬ</u>** ក្រៅវិសាលភាពនៃរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ត្រូវបន្តរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងមាតិកាទី២ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រមនេះ។ |